# សិស្សអន្តរជាតិ
## មគ្គុទេសក៍
## មុនពេលចេញដំណើរ

មគ្គុទេសក៍សិស្ស
ដើម្បីត្រៀមសម្រាប់
ការសិក្សានៅរដ្ឋវិចតូរីយ៉ា (VICTORIA)

ទីក្រុងមែលប៊ិន (Melbourne) ប្រទេសអូស្ត្រាលី

ក្រសួងអប់រំ



VICTORIA
State
Government
Australia

# សូមស្វាគមន៍មកកាន់ទីក្រុងមែលប៊ននិងរដ្ឋវិចតូរីយ៉ា

## ការចូលរួមអបអរសាទរ

ការជ្រើសរើសយកសាលារដ្ឋវិចតូរីយ៉ា គឺជាការបើកផ្លូវគួរឱ្យរំភើបឆ្ពោះទៅកាន់អនាគតរបស់អ្នកហើយមិនយូរប៉ុន្មានយើងនឹងបានស្វាគមន៍អ្នកដោយផ្ទាល់។ មគ្គុទេសក៍នេះមានព័ត៌មានជួយដល់អ្នកឱ្យត្រៀមខ្លួនរួចជាស្រេចដើម្បីធ្វើដំណើរ និងរៀបចំការសិក្សានៅក្នុងរដ្ឋវិចតូរីយ៉ា។ ថ្វីបើព័ត៌មានភាគច្រើនគឺសម្រាប់អ្នកមែន តែឪពុកម្ដាយរបស់អ្នកក៏នឹងយល់ថាមគ្គុទេសក៍នេះមានប្រយោជន៍និងផ្ដល់នូវទំនុកចិត្តដល់ពួកគេដែរ។

អ្នកអាចនឹងបានប្រមូលនូវព័ត៌មានមួយចំនួនរួចទៅហើយ – ប្រហែលព័ត៌មាននោះគឺអំពីសាលាថ្មីរបស់អ្នកកន្លែងដ៏ទាក់ទាញនានាក្នុងក្រុងមែលប៊ន ឬក៏ការរស់នៅក្នុងរដ្ឋវិចតូរីយ៉ាជាដើម។ យើងចង់ឱ្យអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពនិងរីករាយនៅ ពេលអ្នកមកដល់ភ្លាម។ ដូច្នេះ នៅក្នុងនោះអ្នកនឹងឃើញមានគន្លឹះមានប្រយោជន៍ជាច្រើនអំពីជីវិតជាសិស្សរស់នៅក្នុងរដ្ឋវិចតូរីយ៉ា និង អ្វីៗដែលអ្នករំពឹងទុកនៅពេល អ្នកមកដល់ទីនេះ។ ក៏មានផងដែរនូវព័ត៌មានលម្អិតដែលមានប្រយោជន៍ដូចជាគេហទំព័រនិងលេខទូរសព្ទ។

អ្នកហៀបនឹងបោះជំហានដ៏សំខាន់មួយក្នុងជីវិត។ យើងសង្ឃឹមថាអ្នកនឹងយល់ថាមគ្គុទេសក៍នេះមានប្រយោជន៍ក្នុងការណែនាំអ្នកឱ្យស្គាល់ពីសាលានិងផ្ទះថ្មីរបស់អ្នក។

បោះពុម្ពដោយផ្នែកអប់រំអន្តរជាតិ (International Education Division)

ក្រសួងអប់រំ (Department of Education)

ក្រុងមែលប៊ន ខែមិថុនា ឆ្នាំ2023

© រដ្ឋវិចតូរីយ៉ា (ក្រសួងអប់រំ) 2023

សិទ្ធិអ្នកនិពន្ធក្នុងឯកសារនេះគឺជារបស់រដ្ឋវិចតូរីយ៉ា (ក្រសួងអប់រំ) ឬជារបស់ភាគីទីបី (ជាឯកសារភាគីទីបី) ក្នុងករណីឯកសារមួយចំនួន។ គ្មានផ្នែកណាមួយនៃឯកសារនេះ អាចត្រូវផលិតឡើងវិញតាមដំណើរការណាមួយបានឡើយ លើកលែងតែអនុលោមតាមបទប្បញ្ញត្តិនានានៃច្បាប់សិទ្ធិអ្នកនិពន្ធឆ្នាំ 1968 អាជ្ញាប័ណ្ណទទួលបានការអប់រំថ្នាក់ជាតិសម្រាប់សាលារៀន (NEALS) (សូមមើលផ្នែកខាងក្រោម) ឬដោយមានការអនុញ្ញាត។

ស្ថាប័នអប់រំនៅក្នុងប្រទេសអូស្ត្រាលី ដែលមិនដំណើរការឡើងដើម្បីរកប្រាក់ចំណេញ ឬអង្គភាពដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងស្ថាប័នបែបនេះ អាចថតចម្លងនិងផ្សព្វផ្សាយឯកសារផ្សេងៗ ក្រៅពីឯកសាររបស់ភាគីទីបី សម្រាប់គោលបំណងអប់រំរបស់ស្ថាប័ន។

ត្រូវបានអនុញ្ញាតដោយក្រសួងអប់រំ

2 Treasury Place, East Melbourne, Victoria, 3002។

ឯកសារនេះក៏មាននៅលើអ៊ីនធើណិតតាមរយៈ:

www.study.vic.gov.au




# មាតិកា

**ការត្រៀមខ្លួន** **5**
អ្វីៗដែលត្រូវយកមកជាមួយ 5
មុនពេលរៀបចំ 6
បញ្ជីផ្ទៀងផ្ទាត់មុនពេលធ្វើដំណើរ 7
**នៅពេលអ្នកមកដល់** **9**
ការមកដល់ 9
អ្វីៗដែលត្រូវរៀបចំ 10
**ជីវិតរស់នៅក្នុងរដ្ឋវិចតូរីយ៉ានិងក្រុងមែលប៊ន** **13**
បែបផែនជីវិតនិងវប្បធម៌ 13
អាកាសធាតុនិងព័ត៌មានទូទៅ 14
មធ្យោបាយធ្វើដំណើរនិងការធ្វើដំណើរចុះឡើង 16
**ការសិក្សានៅក្នុងរដ្ឋវិចតូរីយ៉ា** **19**
ប្រព័ន្ធសាលារដ្ឋវិចតូរីយ៉ា 19
ការថែរក្សាសុខភាពរបស់អ្នក 20
សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នក 22
ការសង្គ្រោះបន្ទាន់និងស្ថានភាពគួរឱ្យព្រួយបារម្ភ 23
**ធនធានព័ត៌មានអំពីការស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលី** **25**
ផ្ទះស្នាក់នៅរបស់អ្នកឆ្ងាយពីស្រុកកំណើតរបស់អ្នក 25
មុនពេលអ្នកមកដល់ 28
ការមកដល់ផ្ទះដែលអ្នកត្រូវស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលី 29
ការណែនាំឱ្យស្គាល់ពីក្រុមគ្រួសារអូស្ត្រាលីដែលអ្នកត្រូវស្នាក់នៅជាមួយ 29
ជីវិតស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលី 31
សុវត្ថិភាពផ្ទាល់ខ្លួននិងការទំនាក់ទំនង 32
ការធ្វើដំណើរ ការខកខានមិនបានត្រឡប់មកផ្ទះពេលយប់និងភ្ញៀវមកលេង 32
**ព័ត៌មានដែលមានប្រយោជន៍** **34**



# ការត្រៀមខ្លួន

មានចំណុចសំខាន់ជាច្រើនដែលអ្នកគួររៀបចំឱ្យបានរួចរាល់មុនពេលធ្វើដំណើរមកកាន់រដ្ឋវិចតូរីយ៉ា។ ផ្នែកនេះរួមបញ្ចូលនូវព័ត៌មាន ការណែនាំពីការរៀបចំអីវ៉ាន់ និងបញ្ជីផ្ទៀងផ្ទាត់ការធ្វើដំណើរចំនួនពីរ ដើម្បីជួយដល់អ្នកឱ្យដំណើរការបានទៅដោយរលូន។

## តើត្រូវយកអ្វីទៅខ្លះ

មុនពេលរៀបចំសូមសួរនាំក្រុមហ៊ុនអាកាសចរណ៍របស់អ្នកអំពីទំហំនិងចំនួនគីឡូកំណត់។ ប្រសិនបើអ្នកនឹងស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលី សូមកុំភ្លេចដាក់ទម្រង់ជំនួយការមកដល់របស់អ្នកមួយច្បាប់នៅក្នុងវ៉ាលីយួរដៃរបស់អ្នកព្រមជាមួយនឹងឯកសារធ្វើដំណើរទាំងឡាយរបស់អ្នកផងដែរ។

### សម្លៀកបំពាក់និងរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន

នៅរដ្ឋវិចតូរីយ៉ាមានរដូវផ្សេងៗគ្នាដូច្នេះអ្នកនឹងត្រូវការសម្លៀកបំពាក់ឱ្យបានសមស្របទៅតាមរដូវទាំងនេះ។ សូមកុំភ្លេចរបស់របរថែទាំខ្លួននិងឯកសណ្ឋាននានាដែលអ្នកនឹងយកមកជាមួយ។

ប្រសិនបើអ្នកនឹងស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលីអ្នកនឹងមិនត្រូវការរបស់របរប្រើប្រាស់ក្នុងផ្ទះច្រើននោះទេ។ ជាការល្អត្រូវថតរូបជាមួយក្រុមគ្រួសារ និងមិត្តភក្តិបទចម្រៀងដែលអ្នកចូលចិត្តស្តាប់ ឬ វត្ថុអនុស្សាវរីយ៍តូចៗពីប្រទេសកំណើតរបស់អ្នក។

### ថ្នាំពេទ្យ

ប្រសិនបើអ្នកត្រូវការប្រើប្រាស់ថ្នាំជាប្រចាំសម្រាប់លក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ (ដូចជាជំងឺទឹកនោមផ្អែម ហឺត ឬ ជំងឺត្រអក) សូមវេចខ្ចប់ ថ្នាំទាំងនេះដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យរបស់អ្នកនិងពីប្រវត្តិជំងឺរបស់អ្នកមកជាមួយផង។

### ប្រាក់

ប្រសិនបើអ្នកមិនធ្វើដំណើរជាមួយនឹងក្រុមគ្រួសារទេ ជាការប្រសើរនោះត្រូវយកមកជាមួយនូវសាច់ប្រាក់ប្រហែលជា AUD$400 សម្រាប់ការចំណាយដោយថៃដន្យឬបន្ទាន់នានា។

អ្នកអាចប្តូររូបិយប័ណ្ណបរទេសនៅឯប្រលានយន្តហោះ ហាងប្តូររូបិយប័ណ្ណក្នុងមូលដ្ឋាន ឬ នៅតាមធនាគារ។

### តើខ្ញុំអាចយកអាហារមកជាមួយបានទេ?

អូស្ត្រាលីមានច្បាប់តឹងរឹងអំពីការនាំយកអាហារនិងរបស់របរផ្សេងទៀតដូចជាថ្នាំបុរាណ រុក្ខជាតិ និងរបស់របរសរីរាង្គចូលក្នុងប្រទេស ដើម្បីការពារដល់បរិស្ថានរបស់យើង។ នៅក្នុងករណីជាច្រើនរបស់របរប្រភេទទាំងនេះនឹងត្រូវរឹបអូសយកនៅអាកាសយានដ្ឋាន ដូច្នេះអ្នកគួរព្យាយាមជៀសវាងកុំយកវាមកជាមួយ ហើយត្រូវប្រកាសជានិច្ចពីអ្វីដែលអ្នកយកចូលមកនៅលើប័ណ្ណអ្នកដំណើរចូល។ មន្ត្រីកងកម្លាំងការពារព្រំដែនអូស្ត្រាលីនៅអាកាសយានដ្ឋានអាចផ្តល់ការណែនាំដល់អ្នកពីអ្វីដែលអ្នកអាចយកចូលបាន និង ពីអ្វីដែលអ្នកគួរប្រកាសប្រាប់។

ប្រសិនបើអ្នកសម្រេចយកអ្វីមួយចូលតែអ្នកមិនដឹងច្បាស់នោះ ចាំបាច់ត្រូវប្រកាសវានៅលើប័ណ្ណអ្នកដំណើរចូលរបស់អ្នក ឬ សួរទៅកាន់មន្ត្រីកងកម្លាំងការពារព្រំដែន។ វ៉ាលីរបស់អ្នកនឹងត្រូវពិនិត្យនៅឯព្រលានយន្តហោះ និងឆ្កែហិតក្លិនអាចនឹងត្រូវប្រើដើម្បីពិនិត្យមើលវ៉ាលីអីវ៉ាន់របស់អ្នករកមើលចំណីអាហារ និងរបស់របរហាមឃាត់ផ្សេងៗ។

អាហារអន្តរជាតិភាគច្រើននឹងអាចរកបាននៅក្នុងរដ្ឋវិចតូរីយ៉ា ហើយអ្នកសម្របសម្រួលសិស្សអន្តរជាតិ (ISC) សាលារបស់អ្នក អាចជួយដល់អ្នកដើម្បីស្វែងរកអាហារដែលអ្នកត្រូវការក្រោយពេលដែលអ្នកមកដល់អូស្ត្រាលី។

សម្រាប់ព័ត៌មានបន្ថែមស្តីពីប្រភេទអាហារដែលអ្នកអាចនាំចូលអូស្ត្រាលី

សូមមើល៖ abf.gov.au/entering-and-leaving-australia/can-you-bring-it-in



# មុនពេលអ្នករៀបចំអីវ៉ាន់

## លិខិតឆ្លងដែនរបស់អ្នក

មើលកាលបរិច្ឆេទផុតកំណត់លើលិខិតឆ្លងដែនរបស់អ្នក និងត្រូវតែប្រាកដថាសុពលភាពរបស់វាមានពេញមួយរយៈពេលនៃទិដ្ឋាការនិស្សិតរបស់អ្នក។ សូមថតចម្លងលិខិតឆ្លងដែននិងទិដ្ឋាការចំនួនពីរច្បាប់។ យកមួយច្បាប់មកជាមួយអ្នក ប៉ុន្តែទុកវាដាច់ដោយឡែកពីច្បាប់ដើម។ ទុកមួយទៀតនៅឯផ្ទះជាមួយក្រុមគ្រួសាររបស់អ្នក។ អ្នកក៏អាចថតលិខិតឆ្លងដែននិងទិដ្ឋាការរបស់អ្នកដោយប្រើទូរសព្ទដៃរបស់អ្នកទុក ធ្វើដូច្នេះអ្នកក៏នឹងមានជាទម្រង់ឌីជីថលមួយច្បាប់ផងដែរ។ ការត្រៀមលក្ខណៈទាំងនេះនឹងជួយដល់អ្នកបានក្នុងករណីដែលអ្នកបាត់ច្បាប់ដើម។

## ការកក់ជើងយន្តហោះ

សូមរង់ចាំរហូតដល់ពេលទិដ្ឋាការសិស្សរបស់អ្នកត្រូវបានផ្តល់និងថ្លៃសិក្សារបស់អ្នកត្រូវបានបង់មុននឹងអ្នករៀបចំផែនការធ្វើដំណើរ។ អ្នកគួរតែកក់សំបុត្រយន្តហោះទៅកាន់ក្រុងមែលប៊ិន ឬ ព្រលានយន្តហោះអាវ៉ាឡុនភ្លាមៗនៅបន្ទាប់ពីនេះ។

ប្រសិនបើអ្នកនឹងស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលីក្រោយពីកក់សំបុត្ររបស់អ្នកភ្លាមឪពុកម្តាយ ឬភ្នាក់ងារអប់រំរបស់អ្នកនឹងតម្រូវឱ្យអ្នកបំពេញទម្រង់ព័ត៌មានលម្អិតពីជើងហោះហើរ ហើយផ្ញើវាតាមអ៊ីមែលទៅកាន់ក្រសួងអប់រំ ដើម្បីឱ្យអ្នកសម្របសម្រួលសិស្សអន្តរជាតិនៅសាលាថ្មីរបស់អ្នកអាចត្រៀមសម្រាប់ការមកដល់របស់អ្នក។

## កំណត់ពេលវេលាមកដល់របស់អ្នក

ដើម្បីជួយដល់អ្នកក្នុងការតាំងទីលំនៅ ជាការប្រសើរបំផុតអ្នកអាចមកដល់មុនមិនឱ្យលើសពីមួយសប្តាហ៍មុនសាលាអ្នកចាប់ផ្តើម។ អ្នកត្រូវតែមកដល់ឱ្យបានមុនថ្ងៃទីមួយនៃវគ្គចូលរៀន(អាស្រ័យទៅលើកាលបរិច្ឆេទចាប់ផ្តើមរបស់អ្នក)។ឪពុកម្តាយរបស់អ្នកគួរតែសរសេរទៅកាន់ក្រសួងអប់រំប្រសិនបើអ្នកមិនអាចមកទាន់ពេល។

សម្គាល់៖ ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់គ្រួសារអូស្ត្រាលីដែលផ្តល់ការស្នាក់នៅ និង លក្ខខណ្ឌតម្រូវផ្នែកទិដ្ឋាការ និស្សិតដែលត្រូវស្នាក់នៅមិនគួរមកដល់លឿនជាងមួយសប្តាហ៍មុនថ្ងៃទីមួយនៃការចាប់ផ្តើមសាលានោះទេ។

## សុខភាពរបស់អ្នក

ប្រវត្តិសុខភាពរបស់អ្នកមានសារៈសំខាន់ត្រូវពិចារណានៅពេលធ្វើដំណើរមកកាន់រដ្ឋវិចតូរីយ៉ា។ អ្នកគួរតែសាកសួរទៅកាន់ក្រសួងអន្តោប្រវេសន៍អូស្ត្រាលីស្តីពីលក្ខខណ្ឌតម្រូវផ្នែកសុខភាពមុននឹងចាកចេញពីប្រទេសរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌតម្រូវផ្នែកសុខភាព សូមមើល៖ immi.homeaffairs.gov.au/help-support/meeting-our-requirements/health

សូមស្នើសុំលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតរបស់អ្នកដោយក្នុងនោះមានបញ្ជាក់ពីឈ្មោះបច្ចេកទេស និងមូលហេតុសម្រាប់ឱសថណាមួយដែលអ្នកគ្រោងនឹងយកមកជាមួយ ឬ អាចនឹងទិញនៅក្នុងប្រទេសអូស្ត្រាលី។ ការរៀបចំឯកសារពីសុខភាពនឹងជួយដល់អ្នកធានានូវការទទួលបានការថែទាំសមស្របនៅពេលស្ថិតក្នុងស្ថានភាពសង្គ្រោះបន្ទាន់។

## ធានារ៉ាប់រងផ្ទាល់ខ្លួន

អ្នកគួរតែបង្ហាញឯកសារធានារ៉ាប់រងការធ្វើដំណើរក្នុងករណីដែលអ្នកត្រូវការការថែទាំផ្នែកសុខភាពក្នុងពេលកំពុងធ្វើដំណើរមកកាន់ប្រទេសអូស្ត្រាលី។ អ្នកក៏នឹងចាំបាច់ត្រូវរៀបចំឱ្យមានការធានារ៉ាប់រងសុខភាពនិស្សិតនៅក្រៅប្រទេស ដែលជាផ្នែកមួយនៃដំណើរការចុះឈ្មោះចូលរៀនរបស់អ្នកផងដែរ។

ក្រសួងអាចនឹងរៀបចំឱ្យមានការធានារ៉ាប់រងសុខភាពសម្រាប់អ្នក ហើយទម្រង់បែបបទពាក្យសុំបានរួមបញ្ចូលជម្រើសនេះ។ ប្រសិនបើអ្នកស្នើសុំការរ៉ាប់រងសុខភាព សូមពិភាក្សាជាមួយ ISC របស់អ្នកនៅពេលអ្នកមកដល់សាលារៀន ដើម្បីរៀបចំឱ្យគេបញ្ជូនប័ណ្ណរ៉ាប់រងសុខភាពរបស់អ្នកទៅកាន់លំនៅដ្ឋានឬសាលារៀនរបស់អ្នក។ ការរ៉ាប់រងរបស់អ្នក ចាប់ផ្តើមមួយសប្តាហ៍មុនកាលបរិច្ឆេទចាប់ផ្តើមវគ្គសិក្សារបស់អ្នក ទោះបីជាអ្នកមិនទាន់មានប័ណ្ណនៅឡើយក៏ដោយ។ ការធានារ៉ាប់រងវេជ្ជសាស្ត្រនេះ ផ្តល់ជូនការរ៉ាប់រងជាមូលដ្ឋាន ដូច្នេះសូមប្រាកដថា អ្នកយល់ដឹងអំពីរាល់ដែនកំណត់និងលក្ខខណ្ឌទាំងអស់។ ការធានារ៉ាប់រងសុខភាពជាបន្ត អាចត្រូវបានរៀបចំឡើងនៅពេលអ្នកមកដល់រដ្ឋវិចតូរីយ៉ា។ ISC របស់អ្នកនឹងជួយអ្នកលើបញ្ហានេះ ប្រសិនបើចាំបាច់។

សម្រាប់ព័ត៌មានបន្ថែមពីធានារ៉ាប់រងសុខភាពសិស្សក្រៅប្រទេស សូមមើល៖ www.studyaustralia.gov.au/en/plan-your-move/overseas-student-health-cover-oshc.html

## សេវាធនាគារ

សំខាន់បំផុតត្រូវប្រាប់ដល់ធនាគារបច្ចុប្បន្នរបស់អ្នកថាអ្នកនឹងធ្វើដំណើរ និងរៀបចំគម្រោងទទួលបានប្រាក់នៅក្នុងប្រទេសអូស្ត្រាលី ឬធ្វើការគិតប្រាក់ជារូបិយប័ណ្ណបរទេស។ ISC ឬគ្រួសារដែលអ្នកស្នាក់នៅជាមួយអាចជួយអ្នកឱ្យបង្កើតគណនីធនាគារនៅក្នុងប្រទេសអូស្ត្រាលី នៅពេលអ្នកមកដល់។

## ទូរសព្ទចល័តឬទូរស័ព្ទដៃ

សូមសាកសួរទៅកាន់ក្រុមហ៊ុនទូរសព្ទដៃ ឬ ក្រុមហ៊ុនសេវាទូរសព្ទរបស់អ្នកថាតើទូរសព្ទរបស់អ្នកនឹងដំណើរការនៅក្នុងប្រទេសអូស្ត្រាលីដែរឬទេ។ អ្នកអាចនឹងត្រូវការស៊ីមថ្មី ឬ ទូរសព្ទដៃរបស់អ្នកដើម្បីប្រើវានៅពេលអ្នកស្ថិតនៅក្នុងប្រទេសអូស្ត្រាលី។

## ឯកសណ្ឋានសាលា

អ្នកអាចចូលទៅកាន់សាលារៀនរបស់អ្នកនៅថ្ងៃដំបូងដោយស្លៀកពាក់សម្លៀកបំពាក់ធម្មតា។ ISC របស់អ្នកនឹងផ្តល់ជូនអ្នកនូវព័ត៌មានអំពីឯកសណ្ឋានក្រោយពេលអ្នកមកដល់ សម្រាប់ជាផ្នែកមួយនៃការប្រជុំណែនាំដំបូង។ អ្នកអាចដឹងថា ការយករបស់របរមួយចំនួនមកតាមខ្លួនអ្នក (ដូចជា ស្បែកជើងស្បែកពណ៌ខ្មៅចងខ្សែជាដើម) គឺអាចនឹងមិនសូវចំណាយប្រាក់ច្រើន ។

## គយនិងការត្រួតពិនិត្យ

កងកម្លាំងការពារព្រំដែនអូស្ត្រាលីមានវិធានការតឹងរឹងចំពោះអ្វីដែលអ្នកអាចយកមកជាមួយចូលក្នុងប្រទេសអូស្ត្រាលីបាន។ ទាំងនេះរាប់បញ្ចូលទាំងចំនួនសាច់ប្រាក់ដែលអ្នកអាចដាក់ជាប់ខ្លួន ថ្នាំវីតាមីន និងឱសថនានា (ឱសថសាស្ត្រ ឬ ឱសថធម្មជាតិ/បុរាណ) អាហារ ផលិតផលសត្វនិងសត្វចិញ្ចឹម។

សម្រាប់ការណែនាំតាមអនឡាញស្តីពីលក្ខខណ្ឌតម្រូវនានារបស់គយអូស្ត្រាលី សូមមើល៖ immi.homeaffairs.gov.au/entering-and-leaving-australia/entering-australia

## ការត្រឡប់មកផ្ទះវិញ

អ្នកត្រូវស្នាក់នៅក្នុងរដ្ឋវិចតូរីយ៉ារហូតដល់មួយថ្ងៃបន្ទាប់ពីការបិទបញ្ចប់វគ្គសិក្សារបស់សាលា។ ឪពុកម្តាយរបស់អ្នកគួរសរសេរលិខិតទៅកាន់ក្រសួងអប់រំប្រសិនបើអ្នកចាំបាច់ត្រូវចាកចេញពីប្រទេសអូស្ត្រាលីឆាប់ជាងនេះ។



# បញ្ជីផ្ទៀងផ្ទាត់មុនពេលធ្វើដំណើរ

## ត្រៀមខ្លួនសម្រាប់ការធ្វើដំណើរ

- ✓ ទទួលបានទិដ្ឋាការសិស្សនិងបានពិនិត្យមើលគ្រប់លក្ខខណ្ឌទាំងអស់
- ✓ លិខិតឆ្លងដែនមានសុពលភាពរហូតដល់ពេលទិដ្ឋាការសិស្សរបស់អ្នកផុតកំណត់
- ✓ ច្បាប់ថតចម្លងនៃលិខិតឆ្លងដែនរបស់អ្នកនិងទិដ្ឋាការត្រូវបានទុកដាក់ដោយសុវត្ថិភាព និងបានផ្ញើទុកជាមួយក្រុមគ្រួសារ
- ✓ ជើងយន្តហោះត្រូវបានកក់ដើម្បីឱ្យដល់មុនពេលការសិក្សាចាប់ផ្តើម(មិនលើសពីមួយសប្តាហ៍សម្រាប់សិស្សដែលស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលី)
- ✓ សាលាបានជូនដំណឹងលម្អិតស្តីពីការមកដល់ ដើម្បីឱ្យមានមនុស្សអាចមកជួបអ្នកនៅព្រលានយន្តហោះបាន (សម្រាប់តែសិស្សស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលីតែប៉ុណ្ណោះ)
- ✓ ទទួលបានឯកសារប្រវត្តិសុខភាពនិងលិខិតបញ្ជាក់ពីគ្រូពេទ្យប្រសិនបើចាំបាច់
- ✓ ធានារ៉ាប់រងការធ្វើដំណើរនិងសុខភាពត្រូវបានរៀបចំរួចរាល់
- ✓ ធនាគារត្រូវបានជូនដំណឹងពីប្រតិបត្តិការដែលអ្នកនឹងធ្វើឡើងនៅក្នុងប្រទេសអូស្ត្រាលី
- ✓ សេវាទូរសព្ទដៃអាចប្រើប្រាស់បាននិងគិតថ្លៃនៅក្នុងប្រទេសអូស្ត្រាលីត្រូវបានបញ្ជាក់
- ✓ ព័ត៌មានពីឯកសណ្ឋានបានរកឃើញនៅលើគេហទំព័រសាលារួចហើយ

## ត្រូវរៀបចំអ្វីខ្លះ

- ✓ វ៉ាលីអីវ៉ាន់របស់អ្នកមានទំហំនិងចំនួនគីឡូស្របទៅតាមការកំណត់របស់ក្រុមហ៊ុនអាកាសចរណ៍
- ✓ ឯកសារធ្វើដំណើរនិងទម្រង់ជំនួយពេលមកដល់ (សម្រាប់សិស្សស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលី) ដាក់នៅក្នុងវ៉ាលីយួរដៃ
- ✓ រាល់របស់របរជាឯកសណ្ឋានស្តង់ដាសាលា (ឧ.ទា. ស្បែកជើងប៉ូពណ៌ខ្មៅ)
- ✓ សម្លៀកបំពាក់សមស្របសម្រាប់អាកាសធាតុនៅរដ្ឋវិចតូរីយ៉ា
- ✓ ប្រវត្តិសុខភាព លិខិតបញ្ជាក់ពីគ្រូពេទ្យ និងរាល់ឱសថប្រើប្រាស់ជាប្រចាំ
- ✓ ច្បាប់ថតចម្លងនៃឯកសារធានារ៉ាប់រងការធ្វើដំណើរនិងសុខភាព
- ✓ តម្លៃប្រហែល AUD$400 ជាសាច់ប្រាក់ប្រសិនបើអ្នកធ្វើដំណើរដោយពុំមានក្រុមគ្រួសារមកជាមួយទេនោះ
- ✓ វត្ថុអានុស្សាវរីយ៍ពីផ្ទះ រូបថត និងតន្ត្រីដែលអ្នកចូលចិត្តបំផុត
- ✓ ពុំមានរបស់របរហាមឃាត់

## កាលបរិច្ឆេទពីវគ្គសិក្សាសាលារដ្ឋវិចតូរីយ៉ា

| កាលបរិច្ឆេទពីវគ្គសិក្សា | 2024 | 2025 | 2026 | 2027 |
|---|---|---|---|---|
| ត្រីមាសទី 1 | 29 មករា* – 28 មិនា | 28 មករា* – 4 មេសា | 27 មករា* – 2 មេសា | 27 មករា* – 25 មិនា |
| ត្រីមាសទី 2 | 15 មេសា - 28 មិថុនា | 22 មេសា - 4 កក្កដា | 20 មេសា - 26 មិថុនា | 12 មេសា - 25 មិថុនា |
| ត្រីមាសទី 3 | 15 កក្កដា - 20 កញ្ញា | 21 កក្កដា - 19 កញ្ញា | 13 កក្កដា - 18 កញ្ញា | 12 កក្កដា - 17 កញ្ញា |
| ត្រីមាសទី 4 | 7 តុលា – 20 ធ្នូ | 6 តុលា – 19 ធ្នូ | 5 តុលា – 18 ធ្នូ | 4 តុលា – 17 ធ្នូ |

*ថ្ងៃដំបូងនៃត្រីមាសទី 1 គឺជាថ្ងៃទំនេររបស់សិស្សនៅតាមសាលារដ្ឋវិចតូរីយ៉ា ដើម្បីផ្តល់ពេលសម្រាប់ការធ្វើផែនការសម្រាប់ការមកដល់របស់សិស្សានុសិស្ស។ សូមបញ្ជាក់ទៅកាន់ ISC របស់អ្នកពីកាលបរិច្ឆេទតម្រូវឱ្យចាប់ផ្តើម។



# នៅពេលអ្នកមកដល់

មគ្គុទេសក៍ក្នុងផ្នែកនេះ លើកឡើងអំពីការរំពឹងទុកនៅពេលអ្នកមកដល់ទីនេះដំបូង។ ISC របស់អ្នកនឹងជួយអ្នកក្នុងការចូលស្នាក់នៅតាមផ្ទះ និងជីវិតសិក្សា។ មានរឿងជាច្រើនដែលត្រូវរៀបចំ ប៉ុន្តែសូមកុំបារម្ភប្រសិនបើអ្នកមិនប្រាកដពីអ្វីដែលត្រូវធ្វើ។ អ្នកនឹងទទួលបានជំនួយដ៏ច្រើនលើសលប់។

## ការមកដល់

ការត្រៀមខ្លួនចុះចតនៅក្នុងក្រុងមែលប៊ិនពិតជាគួរឱ្យរំភើប។ ត្រូវប្រាកដថាអ្នកស្តាប់រាល់ព័ត៌មានដែលក្រុមហ៊ុនអាកាសចរណ៍ផ្តល់អំពីគយ និង អន្តោប្រវេសន៍អូស្ត្រាលី ដើម្បីឱ្យអ្នកអាចឆ្លងកាត់អាកាសយានដ្ឋានបានឆាប់។

### នៅឯអាកាសយានដ្ឋាន

យើងយល់ថាសិស្សស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលីត្រូវការការគាំពារតិចតួចនៅពេលពួកគេមកដល់អូស្ត្រាលីដំបូងរួមទាំងការមកជួបស្វាគមន៍នៅឯអាកាសយានដ្ឋានផងដែរ។ ប្រសិនបើអ្នកនឹងរស់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលី ត្រូវតែប្រាកដថាអ្នកបានរៀបចំទម្រង់ជំនួយពេលមកដល់ដាក់ក្នុងវ៉ាលីយួរដៃរបស់អ្នក។ ឯកសារនេះប្រាប់អ្នកឱ្យដឹងពីអ្នកដែលនឹងមកទទួលអ្នកនៅឯអាកាសយានដ្ឋានក្រុងមែលប៊ិន ឬអាវ៉ាឡុន និង ពីទីកន្លែងត្រូវជួបគ្នា។ អាសយដ្ឋានផ្ទះដែលអ្នកត្រូវស្នាក់នៅ និង លេខទូរសព្ទទំនាក់ទំនងបន្ទាន់ក៏មានក្នុងនោះដែរក្រែងមានបញ្ហាអ្វីមួយកើតឡើង។

សូមមើលទំព័រទី 29 សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការមកដល់សម្រាប់សិស្សស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលី។

### ការទូរសព្ទមកលេងផ្ទះ

អ្នកប្រហែលជានឹងចង់ទូរសព្ទមកលេងក្រុមគ្រួសារឬមិត្តភក្តិនៅឯប្រទេសកំណើតនៅពេលអ្នកមកដល់អូស្ត្រាលីដំបូង។ ប្រសិនបើក្រុមហ៊ុនសេវាទូរសព្ទចល័តឬទូរសព្ទដៃរបស់អ្នកមានសេវាពីអូស្ត្រាលី អ្នកអាចនឹងប្រើប្រាស់ទូរសព្ទដៃផ្ទាល់ខ្លួនរបស់អ្នកបាន។ ប្រសិនបើអ្នកនឹងស្នាក់នៅតាមផ្ទះជាមួយនឹងក្រុមគ្រួសារអូស្ត្រាលី អ្នកក៏អាចសាកសួរក្រុមគ្រួសារអូស្ត្រាលីដែលផ្តល់ការស្នាក់នៅពីការប្រើប្រាស់វ៉ៃហ្វៃរបស់គេ ឬ ប្រើប្រាស់ខ្សែទូរសព្ទលើតុរបស់គេ។

### ការប្រើប្រាស់លុយកាក់

ប្រសិនបើអ្នកត្រូវការលុយកាក់នៅពេលអ្នកមកដល់ដំបូង វាងាយបំផុតត្រូវប្រើធនាគាររបស់អ្នក ឬប័ណ្ណឥណទានរបស់អ្នក។ ស្ទើរតែគ្រប់ម៉ាស៊ីនអេធីអឹម (ATMs) ទាំងអស់នៅក្នុងប្រទេសអូស្ត្រាលីទទួលយកប័ណ្ណ ‘PLUS’, ‘Maestro’ និងប័ណ្ណ ‘Cirrus’។ សូមពិនិត្យមើលលើប័ណ្ណរបស់អ្នកពីស្លាកសញ្ញាទាំងនេះដែលទទួលស្គាល់ជាអន្តរជាតិ។

> វាជាផ្នែកដ៏សំខាន់នៃតួនាទីរបស់យើងដែលត្រូវធ្វើឱ្យសិស្សានុសិស្សមានអារម្មណ៍កក់ក្តៅ សុវត្ថិភាព និង សប្បាយចិត្ត។ ខ្ញុំជួបគ្រប់សិស្សទាំងអស់នៅពេលដែលពួកគេមកដល់ ហើយប្រាប់ពួកគេថាគេអាចទូរសព្ទមកខ្ញុំបានគ្រប់ពេលពីការព្រួយបារម្ភទាំងឡាយដែលគេមាន។ ខ្ញុំស្គាល់ក្រុមគ្រួសារអូស្ត្រាលីដែលនឹងត្រូវទទួលការស្នាក់នៅតាមផ្ទះទាំងអស់ ហើយយើងរួមគ្នាជួយដល់សិស្សានុសិស្សឱ្យយល់ពីការធ្វើដំណើរក្នុងស្រុក ការប្រើប្រាស់ធនាគារ និងការដើរទិញអីវ៉ាន់។ សិស្សនឹងត្រូវនាំទៅកាន់មជ្ឈមណ្ឌលភាសាអង់គ្លេសរបស់គេនៅក្នុងថ្ងៃទីមួយ ហើយពួកគេជាធម្មតាបង្កើតមិត្តភក្តិបានយ៉ាងលឿន។ ក្រោយមក ខ្ញុំនឹងជួយដល់សិស្សានុសិស្សឱ្យបញ្ជាក់ពីមុខវិជ្ជាសិក្សាដែលគេជ្រើសរើស ទិញឯកសណ្ឋានសិស្សនិងសៀវភៅរបស់ពួកគេ។
>
> អ្វីដែលសំខាន់នោះគឺសិស្សានុសិស្សត្រូវដឹងថាពួកគេអាចសួរសំណួរនានាបាន ហើយគ្រប់គ្នាមានឆន្ទៈនឹងជួយដល់ពួកគេ! ប្រសិនបើវាពិបាកនិយាយនិងយល់ភាសាអង់គ្លេសអូស្ត្រាលីនៅពេលដំបូងនោះ ខ្ញុំអាចរកអ្នកបកប្រែឱ្យអ្នកបាន។
>
> – **Cathy Di Battista**
> អ្នកសម្របសម្រួលសិស្សអន្តរជាតិ
> **Strathmore Secondary College**

# របស់របរដែលត្រូវរៀបចំ

## រក្សាទំនាក់ទំនងជានិច្ច

បើទោះបីជាទូរសព្ទដៃរបស់អ្នកមានសេវាក៏ដោយក៏ការទិញស៊ីមអូស្ត្រាលីប្រើប្រាស់មានតម្លៃថ្លៃជាងដែរ។ អ្នកអាចធ្វើបែបនេះបាននៅស្ទើរតែគ្រប់ផ្សារទំនើបនិងមជ្ឈមណ្ឌលលក់ទំនិញទាំងអស់។

មធ្យោបាយប្រសើរបំផុតដែលត្រូវរក្សាទំនាក់ទំនងនោះគឺការប្រើកម្មវិធី Whatsapp, WeChat, Skype, Viber, Facetime ឬ កម្មវិធីអ្វីមួយដែលស្រដៀងគ្នានេះដោយប្រើប្រាស់វ៉ៃហ្វៃអ៊ីនធើណិតតាមផ្ទះដែល អ្នកស្នាក់នៅ ឬ តាមរយៈកញ្ចប់ទិន្នន័យទូរសព្ទដៃរបស់អ្នកនៅពេលដែលអ្នកមិនស្ថិតនៅផ្ទះ។

ប័ណ្ណទូរសព្ទសម្រាប់ការហៅចេញក្រៅប្រទេសក៏ងាយស្រួលរកទិញដែរ។ប័ណ្ណទូរសព្ទទាំងនេះអាចឱ្យអ្នកហៅទូរសព្ទទៅក្រៅប្រទេសបានក្នុងតម្លៃថោក។

ប្រសិនបើអ្នកស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលីនោះក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយក៏យល់ព្រមឱ្យអ្នកសងថ្លៃការហៅទូរសព្ទទៅក្រៅប្រទេសធ្វើឡើងតាមខ្សែទូរសព្ទពីផ្ទះផងដែរ។ បើទោះបីជាធ្វើបែបនេះបានមែន ជាការប្រសើរអ្នកត្រូវសុំគ្រប់ពេលដែលអ្នកប្រើប្រាស់ខ្សែទូរសព្ទក្នុងផ្ទះ ដើម្បីចៀសវាងការភាន់ច្រលំនានាដែលអាចកើតឡើង។

នៅពេលសមាជិកក្រុមគ្រួសារអ្នកណាម្នាក់ចង់ទាក់ទងមកអ្នកនៅក្នុងប្រទេសអូស្ត្រាលីពួកគេគួរតែប្រើប្រាស់ក្បាល 00 11 61 ដើម្បីហៅទូរសព្ទមកអ្នកតាមខ្សែទូរសព្ទលើតុ ឬ ក្បាល +61 ដើម្បីទូរសព្ទមកកាន់ទូរសព្ទដៃរបស់អ្នក។ នៅពេលមានការហៅទូរសព្ទពីក្រៅប្រទេសមក មិនចាំវាយលេខសូន្យ (0) នៅមុនលេខកូដតំបន់រដ្ឋវិចតូរីយ៉ា ឬ លេខទូរសព្ទដៃរបស់អ្នក។ ដូច្នេះអ្នកនៅក្រៅអូស្ត្រាលីគួរតែចុចលេខ៖ (00 11 ឬ +) 61 3 (លេខប្រាំបីតួក្នុងស្រុក) ដើម្បីហៅទៅកាន់ខ្សែទូរសព្ទលើតុក្នុងរដ្ឋវិចតូរីយ៉ា ឬ (00 11 ឬ +) 61 (ប្រាំបួនលេខ, ចាប់ផ្ដើមដោយលេខ4) ដើម្បីហៅទៅកាន់លេខទូរសព្ទដៃរបស់អ្នក។

ក៏មានកម្មវិធីអនឡាញដែលអាចជួយបានផងដែរតាម https://www.dialingcode.com/

## ការធ្វើដំណើរក្នុងក្រុង

ប្រព័ន្ធមធ្យោបាយធ្វើដំណើរសាធារណៈរដ្ឋវិចតូរីយ៉ាប្រើប្រាស់ការលក់សំបុត្រអេឡិចត្រូនិកបង់ថ្លៃមុន។ ប្រសិនបើអ្នកនឹងធ្វើដំណើរតាមរថភ្លើង ត្រាំ ឬ រថយន្តក្រុង អ្នកនឹងត្រូវការប័ណ្ណ Child myki card។ ប័ណ្ណទាំងនេះត្រូវបានដាក់លក់នៅតាមស្ថានីយ៍រថភ្លើង ហាងលក់រាយ និងតាមអនឡាញ។ ព័ត៌មានបន្ថែមពីមធ្យោបាយធ្វើដំណើរសាធារណៈមាននៅផ្នែកខាងក្រោយក្នុងមគ្គុទេសក៍នេះ។

## សម្ភារសិក្សា

ភ្លាមៗក្រោយពេលអ្នកមកដល់អ្នកនឹងចាំបាច់ត្រូវទិញឯកសណ្ឋានសិស្ស សៀវភៅសិក្សា និងសម្ភារសិក្សាដទៃផ្សេងទៀត (ដូចជា កាតាប ប្រអប់អាហារថ្ងៃត្រង់ ឬ សម្ភារការិយាល័យ)។ អ្នកសម្របសម្រួលសិស្សអន្តរជាតិរបស់អ្នកនឹងជួយអ្នកក្នុងរឿងនេះ។

## គណនីធនាគាររបស់អ្នក

អ្នកនឹងស្ថិតនៅក្នុងរដ្ឋវិចតូរីយ៉ាមួយរយៈពេលវែងដូច្នេះអ្នកទំនងជានឹងអាចបើកគណនីធនាគារអូស្ត្រាលីបាន។ ISC របស់អ្នកអាចជួយដល់អ្នកបាននៅក្នុងរឿងនេះ។នៅពេលដែលគណនីធនាគាររបស់អ្នកបើកបានហើយ អ្នក ឬ ឪពុកម្ដាយរបស់អ្នកអាចផ្ទេរប្រាក់ពីប្រទេសកំណើតរបស់អ្នកមកបាន។

ប្រសិនបើអ្នកមានគម្រោងធ្វើការក្រៅម៉ោង ប្រាក់ឈ្នួលក៏អាចបើកបានតាមរយៈគណនីនេះដែរ។ ជាការប្រសើរដែលអ្នកមិនត្រូវយកចំនួនសាច់ប្រាក់ចូលមកក្នុងប្រទេសអូស្ត្រាលីច្រើនទេ ទោះជាយ៉ាងណា ប្រសិនបើអ្នកយកមក ISC របស់អ្នកអាចរក្សាលុយនេះទុកក្នុងទូដែកសាលាឱ្យអ្នកបានរហូតដល់ពេលអ្នកបើកគណនីធនាគារ។



> នៅពេលខ្ញុំបានឮពីដំបូងថា ខ្ញុំនឹងមកកាន់ប្រទេសអូស្ត្រាលី ខ្ញុំរំភើបខ្លាំងណាស់! វាជាក្ដីសុបិន្តរបស់ខ្ញុំដែលមានតាំងពីពេលខ្ញុំនៅតូចហើយទីបំផុតទៅវាបានក្លាយជាការពិតហើយ។
>
> ខ្ញុំយល់ថាខ្ញុំមានសំណាងខ្លាំងណាស់! ការសម្របខ្លួនទៅនឹងសាលាថ្មីនិងការបង្កើតមិត្តភក្តិមានភាពងាយស្រួលប្រសិនបើអ្នកមិនម៉ត់ចត់ពេកទេនោះ ព្រោះថាពលរដ្ឋអូស្ត្រាលីច្រើនតែជាអ្នកមិនសូវសាំញ៉ាំហើយពួកគេចូលចិត្តលេងសើចច្រើន។
>
> – **Katlyn (Thi Hoang Anh) Nguyen Victorian** ជាសិស្សអន្តរជាតិដែលបានបញ្ចប់ការសិក្សា។



# ជីវិតក្នុងរដ្ឋវិចតូរីយ៉ានិងក្រុងមែលប៊ន

រដ្ឋវិចតូរីយ៉ាល្បីខាងការលើកកម្ពស់វប្បធម៌ផ្សេងៗគ្នា ហើយសិស្សានុសិស្សដូចរូបអ្នកគឺជាផ្នែកមួយដ៏ធំក្នុងរឿងនោះ។ អ្នកប្រហែលជាបានដឹងហើយថា មែលប៊នគឺជាទីក្រុងទំនើបទាន់សម័យដែលអ្នកអាចនឹងពេញចិត្តជាមួយនឹងចំណាប់អារម្មណ៍និងសកម្មភាពខុសផ្សេងៗគ្នាជាច្រើន។ មគ្គុទេសក៍ក្នុងផ្នែកនេះមានព័ត៌មានស្ដីអំពីជីវិតរស់នៅក្នុងក្រុងមែលប៊ននិងរដ្ឋវិចតូរីយ៉ា។ យើងក៏បានរួមបញ្ចូលនូវគេហទំព័រមួយចំនួនដែលអ្នកអាចទទួលបាននូវព័ត៌មានបន្ថែមទៀតផងដែរ។

## របៀបរស់នៅនិងវប្បធម៌

### ការកម្សាន្តសប្បាយ សកម្មភាពនានា និងភាពសប្បាយរីករាយ

អ្នកធ្វើដំណើរមកកាន់រដ្ឋវិចតូរីយ៉ាដើម្បីទទួលបានគុណភាពអប់រំប៉ុន្តែពេលវេលារបស់អ្នកនៅទីនេះ ក៏អាចមានភាពសប្បាយរីករាយនិងរំភើបផងដែរ។ មិត្តភក្តិនៅសាលារបស់អ្នក និងក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយនឹងចង់ឱ្យអ្នកចូលរួមក្នុងសកម្មភាពសប្បាយៗជាច្រើននៅក្បែរៗនិងនៅទូទាំងរដ្ឋវិចតូរីយ៉ា។ មិត្តភក្តិថ្មីៗទាំងឡាយរបស់អ្នកអាចនឹងមានសកម្មភាពលេងកម្សាន្តក្រៅផ្ទះ (ឧ.ទា ជិះកង់ និងហែលទឹកលេង) ឬរីករាយជាមួយនឹងការញ៉ាំអាហារខាងក្រៅ មើលភាពយន្ត ឬ ដំណើរ ស្វែងយល់ពីទីក្រុង។ ចាំបាច់ណាស់ដែលអ្នកចូលរួមក្នុងក្រុមកីឡា ព្រះវិហារក្នុងមូលដ្ឋានអ្នករស់នៅ ក្រុមតន្ត្រី ឬក្រុមល្ខោន។ ពលរដ្ឋវិចតូរីយ៉ាក៏ជក់ចិត្តនឹងសម្ព័ន្ធបាល់ទាត់អូស្ត្រាលីផងដែរ (AFL) ហើយអាចនឹងចង់លើកទឹកចិត្តដល់អ្នកឱ្យ ចូលរួមប្រកួត ឬជ្រើសរើសក្រុមដើម្បីតាមដានផងដែរ។

### សហគមន៍ពហុវប្បធម៌ សុវត្ថិភាព និងមេត្រីភាព

មែលប៊នគឺជាទីក្រុងពហុវប្បធម៌បំផុតមួយរបស់ប្រទេសអូស្ត្រាលី ដែលមានប្រវត្តិយូរលង់ក្នុងការទទួលយកមនុស្សមកពីគ្រប់ជាតិសាសន៍ និងគ្រប់សញ្ជាតិ ហើយជាងពាក់កណ្ដាលនៃពលរដ្ឋវិចតូរីយ៉ា មានចំណងគ្រួសារផ្ទាល់នៅបរទេស។ សាលាទាំងអស់ផ្ដល់តម្លៃនិងគោរពចំពោះបុគ្គលនិងពហុវប្បធម៌ ហើយអ្នកនឹងអាចរក្សាបាននូវទំនាក់ទំនងជាមួយនឹងក្រុមគ្រួសារតាមរយៈសកម្មភាពវប្បធម៌ទាំងខាងក្នុងនិងខាងក្រៅសាលា។ មនុស្សច្រើនរាប់មិនអស់ពេញចិត្តចូលរួមក្នុងពិធីបុណ្យនានាដូចជា បុណ្យចូលឆ្នាំចិន (Lunar New Year) បុណ្យពន្លឺឥណ្ឌា (Diwali Indian Festival of Light) បុណ្យពហុវប្បធម៌ប៉ាកូ (Pako Festa) បុណ្យអ៊ីស្ទើរ (Easter Festival) និងបុណ្យសប្ដាហ៍ពហុវប្បធម៌ (Cultural Diversity) ពេលខ្លះហាក់ដូចជាមានពិធីបុណ្យរាល់សប្ដាហ៍តែម្ដង!

### សិស្សនៅតាមក្រុងនានារបស់រដ្ឋវិចតូរីយ៉ា

មជ្ឈមណ្ឌលទេសចរណ៍ កសិកម្ម និង ឧស្សាហកម្ម មានលក្ខណៈពិសេសក្នុងចំណោមទីក្រុងនិស្សិតរស់នៅមានលក្ខណៈរីកចម្រើនជាច្រើនរបស់រដ្ឋវិចតូរីយ៉ា។ មនុស្សដែលរស់នៅក្នុងសហគមន៍ទាំងនេះគឺមានចិត្តទូលាយ រួសរាយ រាក់ទាក់ និងធ្វើឱ្យអ្នកចំណូលថ្មីមានអារម្មណ៍កក់ក្ដៅ។

រដ្ឋវិចតូរីយ៉ាផ្ដល់នូវវប្បធម៌ទំនើបរីកចម្រើន និងជម្រើសទូលំទូលាយសម្រាប់សកម្មភាពក្រៅសាលា។ ប្រជាជននៅក្នុងរដ្ឋនេះមានភាពរួសរាយរាក់ទាក់ និងស្រស់ស្រាយ ប៉ុន្តែក៏មានភាពត្រេកត្រអាលចំពោះបំណងប្រាថ្នារបស់ពួកគេដែរ។ ប្រជាជនរដ្ឋវិចតូរីយ៉ាមានភាពល្បីល្បាញខាងការនិយមចូលចិត្តអាហារសេកលសិល្បៈ វប្បធម៌ កីឡា និងសកម្មភាពក្នុងឬក្រៅផ្ទះ។



# ព័ត៌មានពីអាកាសធាតុនិងព័ត៌មានទូទៅ

## សុវត្ថិភាពផ្ទាល់ខ្លួន

រដ្ឋវិចតូរីយ៉ាគឺជាសហគមន៍មួយដែលមានមេត្រីភាព សុវត្ថិភាពនិង មានលក្ខណៈពហុវប្បធម៌។ អ្នកនឹងមកឃើញថាក្រុងមែលប៊ិនស្អាតមានអនាម័យ ស្ងប់ស្ងាត់ និង ស្រស់ស្រាយដោយសេចក្តីអំណរ។ មិនថាអ្នកមានសំណួរតូចតាចប៉ុណ្ណាទេ ប្រសិនបើអ្នកមានការព្រួយបារម្ភសូមសួរវាទៅកាន់លោកគ្រូ អ្នកគ្រូ ក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយ ឬ ISC របស់អ្នក។ ពួកគេត្រៀមខ្លួនជាស្រេចនឹងជួយដល់អ្នកឱ្យមានអារម្មណ៍សប្បាយរីករាយនិងសុវត្ថិភាព។ អ្នកក៏នឹងទទួលបានសេវាគាំពារ សិស្សដែលក្នុងនោះក៏មានលេខទូរសព្ទសង្គ្រោះបន្ទាន់ផងដែរ។

ព្រះអាទិត្យនិងការជិះស្គីលើទឹកជាសកម្មភាពដ៏គួរឱ្យត្រេកត្រអាលសម្រាប់ទេសចរក៏ដូចជាអ្នកក្នុងស្រុកដែរ ប៉ុន្តែក៏អាចមានហានិភ័យផងដែរ។ ជានិច្ចជាកាលអ្នកគួរតែប្រុងប្រយ័ត្នដើម្បីការពារស្បែករបស់អ្នក ជាពិសេសនៅពេលស្ថិតនៅតាមឆ្នេរសមុទ្រ ឬ តាមអាងហែលទឹក។ ពន្លឺព្រះអាទិត្យនៅអូស្ត្រាលីអាចមានកំដៅខ្លាំងនៅរដូវក្តៅដែលនេះខុសពីបណ្តាប្រទេសផ្សេងទៀត ដែលសន្ទស្សន៍យូវី (UV) អាចនឹងមានកម្រិតខ្ពស់ពេញមួយឆ្នាំ។ សម្លៀកបំពាក់ដៃវែង ក្រែមការពារកំដៅថ្ងៃ និងមួកមានសារៈសំខាន់ណាស់ ជាពិសេសក្នុងអំឡុងពេលថ្ងៃក្តៅខ្លាំងបំផុត។

ជ្រើសរើសតែឆ្នេរលេងស្គីលើទឹកណាដែលមាន អ្នកល្បាតសម្រាប់ការហែលទឹកលេងដែលមានក្រុមជួយសង្គ្រោះប្រចាំការ។ ប្រសិនបើអ្នកមិនចេះហែលទឹកសូមប្រាប់ដល់ក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយ ឬមិត្តភក្តិរបស់អ្នកដែលជាអ្នកអញ្ជើញអ្នកទៅអាងហែលទឹក ឬ ឆ្នេរសមុទ្រ ដើម្បីឱ្យពួកគេអាចជួយមើលថែអ្នកឱ្យមានសុវត្ថិភាពបាន។ មានព័ត៌មានច្រើនបន្ថែមទៀតអំពីសុវត្ថិភាពឆ្នេរសមុទ្រនៅលើអនឡាញដែលអាចមើលបានតាម beachsafe.org.au



## ម៉ោងខុសគ្នា

រដ្ឋវិចតូរីយ៉ាស្ថិតនៅក្នុងល្វែងម៉ោងស្តង់ដាអូស្ត្រាលីភាគខាងកើត GMT+10 (AEST) នៃម៉ោងអន្តរជាតិ។ នៅក្នុងខែក្តៅខ្លាំង នាឡិកាបង្វិលថែមមួយម៉ោងទៅមុខដែលធ្វើឱ្យពេលថ្ងៃមានរយៈពេលវែងជាងមុន។ អ្នកអាចស្វែងយល់បន្ថែមទៀតបានពីភាពខុសគ្នានៃពេលវេលានៅក្នុងឆ្នាំតាម timeanddate.com/worldclock

## ថ្ងៃឈប់សម្រាកជាសាធារណៈ

ថ្ងៃឈប់សម្រាកសាធារណៈរបស់រដ្ឋវិចតូរីយ៉ាមានបោះពុម្ពផ្សាយអនឡាញតាម business.vic.gov.au/victorian-public-holidays-and-daylight-saving/victorian-public-holidays

## ធ្វើការនៅរដ្ឋវិចតូរីយ៉ា

ទិដ្ឋាការសិស្សអន្តរជាតិរបស់អ្នក អនុញ្ញាតឱ្យអ្នកធ្វើការក្រៅម៉ោងបាន នៅពេលអ្នកសិក្សា។ ប្រសិនបើអ្នកសម្រេចចិត្តថាចូលធ្វើការក្រៅម៉ោង ឬការងារធម្មតាខ្លះ អ្នកត្រូវតែចាប់ផ្តើមការសិក្សារបស់អ្នកមុនពេលចាប់ផ្តើមការងារ។

ការធ្វើការងារក្រៅម៉ោងសិក្សាអាចនឹងប៉ះពាល់ការសិក្សារបស់អ្នក។ សូមពិភាក្សាជាមួយនឹងអ្នកសម្របសម្រួលសិស្សអន្តរជាតិរបស់អ្នកមុននឹងអ្នកដាក់ពាក្យសុំការងារធ្វើ ដើម្បីឱ្យអ្នកអាចសម្របខ្លួនចូលទៅក្នុងសកម្មភាពសិក្សាប្រចាំថ្ងៃបានសិន ហើយបន្តទៅផ្តោតទៅលើការសិក្សារបស់អ្នក។

យើងសូមផ្តល់ការណែនាំដល់អ្នកឱ្យធ្វើការតែនៅចុងសប្តាហ៍ ដោយទុកពេលយប់ក្នុងសប្តាហ៍ឱ្យទំនេរសម្រាប់ការងារសាលា និងការសិក្សា។ អ្នកសម្របសម្រួលសិស្សអន្តរជាតិរបស់អ្នកអាចជួយអ្នកឱ្យទទួលលេខប្រកាសពន្ធអូស្ត្រាលីបាន។ កន្លែងការងារល្បីៗនឹងត្រូវការព័ត៌មាននេះមុននឹងអ្នកអាចចាប់ផ្តើមធ្វើការងារបាន។ 'ការងារផ្តល់ជាសាច់ប្រាក់' ឬ 'ក្រៅបញ្ជី' គឺជាការងារខុសច្បាប់ ហើយអ្នកក៏ពុំទទួលបាន ការការពារត្រឹមត្រូវដែរ ដូច្នេះសូមកុំទទួលយកការងារប្រភេទនេះ។
ពិភាក្សាជាមួយនឹង ISC របស់អ្នកភ្លាម ប្រសិនបើអ្នកព្រួយបារម្ភពីលក្ខខណ្ឌការងាររបស់អ្នក ឬ ប្រសិនបើមានរឿងអ្វីមួយកើតឡើងដែលអ្នកយល់ថាមិនត្រឹមត្រូវ។

## ភ្ញៀវពីប្រទេសកំណើតមកលេង

ឪពុកម្តាយរបស់អ្នកអាចមកលេងអ្នកបានក្នុងអំឡុងពេលអ្នកកំពុងសិក្សានៅទីនេះ។ សូមប្រាប់ទៅដល់ ISC របស់អ្នកអំពីគម្រោងមកលេងរបស់ក្រុមគ្រួសារអ្នក។ ពួកគេអាចសំណូមពរពេលវេលាពិសេសណាមួយនៅសាលាដ៏សមស្របដែលឪពុកម្តាយរបស់អ្នកមកលេងបាន។ ISC របស់អ្នកដឹងពីសណ្ឋាគារនិងអាផាតមិននានាដែលនៅជិតសាលា។

## អាហារនិងទឹក

សិស្សានុសិស្សយកអាហារថ្ងៃត្រង់ អាហារសម្រន់ និងដបទឹកប្រើឡើងវិញបានរបស់គេមកសាលា ដែលពួកគេអាចច្រកឡើងវិញបាននៅសាលា។ នឹងមានម៉ៃក្រូវ៉េវនៅតាមសាលារបស់គេ ប្រសិនបើអាហារដែលគេយកមកនោះត្រូវការកំដៅវា។

ប្រព័ន្ធទឹកស្អាតក្នុងប្រទេសអូស្ត្រាលីមានសុវត្ថិភាពទាំងស្រុងសម្រាប់ញ៉ាំ ដូច្នេះមិនចាំបាច់ទិញទឹកដបទេ។

## សម្លៀកបំពាក់សាលានិងសម្លៀកបំពាក់ធម្មតា

សាលាភាគច្រើនមានឯកសណ្ឋាន ឬសម្លៀកបំពាក់ស្តង់ដារបស់គេដែលអ្នកនឹងតម្រូវឱ្យស្លៀកពាក់ដើម្បីចូលរៀនក្នុងថ្នាក់ ចូលរួមក្នុងព្រឹត្តិការណ៍នានា និងនៅក្នុងថ្ងៃកីឡា។ អ្នកក៏នឹងអាចតម្រូវឱ្យពាក់ឯកសណ្ឋានប្រសិនបើអ្នកធ្វើការក្រៅម៉ោង។ នៅក្រៅសាលានិងការងារ ការស្លៀកពាក់អាចធ្វើបានទៅតាមការពេញចិត្តរបស់អ្នក។ ពលរដ្ឋអូស្ត្រាលីទទួលយកនូវវប្បធម៌ដទៃបាន ដូច្នេះអ្នកនឹងច្រើនតែឃើញមនុស្សម្នាមកពីប្រទេសដទៃស្លៀកពាក់ទៅតាមវប្បធម៌ ឬ សាសនារបស់គេ។

### របស់ចាំបាច់សម្រាប់រដូវក្តៅ៖

- មួក
- វ៉ែនតាការពារកំដៅថ្ងៃ
- ក្រែមការពារកំដៅថ្ងៃ
- អាវយឺត
- សំពត់ខ្លី/ខោខ្លី
- អាវធំរងាសាច់ស្តើង/អាវយឺតរងា



### របស់របរចាំបាច់សម្រាប់រដូវរងា៖

- អាវធំរដូវរងា
- អាវយឺតរងា
- ស្រោមដៃ
- ក្រមា
- ស្បែកជើងស៊ិក



## អាកាសធាតុនិងទីតាំង

ប្រៀបទៅនឹងកន្លែងជាច្រើន អាកាសធាតុនៅរដ្ឋវិចតូរីយ៉ាមានលក្ខណៈមិនខ្លាំងពេកនិងងាយស្រួលរស់នៅ។ តែអាកាសធាតុអាចប្រែប្រួលយ៉ាងរហ័សមានពេលខ្លះប្រែប្រួល លើសពីម្តងក្នុងមួយថ្ងៃ នេះជាឆាតនៃសីតុណ្ហភាពមធ្យមខ្ពស់បំផុតប្រចាំថ្ងៃ។ សីតុណ្ហភាពទាំងនេះខុសៗគ្នាទៅតាមទីតាំង ឧ.ទា. កាន់តែកៀកទៅភ្នំនឹងជាធម្មតាកាន់តែត្រជាក់ស្រួលរស់នៅ។ អ្នកអាចស្វែងរកព័ត៌មានបន្ថែមបានពីអាកាសធាតុក្នុងរដ្ឋវិចតូរីយ៉ានៅលើគេហទំព័រការិយាល័យឧតុនិយម៖ bom.gov.au/vic

| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| **សីតុណ្ហភាពមធ្យមខ្ពស់បំផុត (°C)** | | | | | | | | | | | |
| 25,9 | 25,8 | 23,9 | 20,3 | 16,7 | 14,1 | 13,5 | 15,0 | 17,2 | 19,7 | 22,0 | 24,2 |
| **សីតុណ្ហភាពមធ្យមទាបបំផុត (°C)** | | | | | | | | | | | |
| 14,3 | 14,6 | 13,2 | 10,8 | 8,6 | 6,9 | 6,0 | 6,7 | 8,0 | 9,5 | 11,2 | 12,9 |
| **កម្រិតទឹកភ្លៀងជាមធ្យម (mm)** | | | | | | | | | | | |
| 47,6 | 48,0 | 50,4 | 57,3 | 55,8 | 49,0 | 47,5 | 50,0 | 58,1 | 66,4 | 60,4 | 59,5 |

## អាកាសធាតុតាមរដូវកាល

អាកាសធាតុកម្រិតស្រាលរបស់រដ្ឋវិចតូរីយ៉ាផ្តល់ឱកាសច្រើនលើសលប់សម្រាប់សកម្មភាពក្រៅផ្ទះ និងការរស់នៅដោយសកម្មប្រកបដោយសុខុមាលភាព។ ដូចគ្នាទៅនឹងប្រទេសទាំងអស់នៅភាគខាងត្បូងផែនដីដែរ រដូវនៅប្រទេសអូស្ត្រាលីក៏មានលំដាប់ លំដោយដូចគ្នាដែរពោលគឺ៖

| | | | |
|---|---|---|---|
| **រដូវក្តៅ៖** | **ពីខែធ្នូដល់ខែកុម្ភៈ** | **រដូវស្លឹកឈើជ្រុះ៖** | **ពីខែមីនាដល់ខែឧសភា** |
| **រដូវរងា៖** | **ពីខែមិថុនាដល់ខែសីហា** | **រដូវផ្ការីក៖** | **ពីខែកញ្ញាដល់ខែវិច្ឆិកា** |

# មធ្យោបាយធ្វើដំណើរនិងការធ្វើដំណើរជុំវិញរដ្ឋ

## អ្នកនឹងបានឃើញថាក្រុងមែលប៊ិនមានលក្ខណៈងាយស្រួលធ្វើដំណើរដោយប្រើប្រាស់ប្រព័ន្ធមធ្យោបាយធ្វើដំណើរសាធារណៈដ៏ល្អប្រណិត។

បណ្ដាញរថភ្លើង ត្រាំ និងរថយន្តក្រុងផ្ដល់ការចេញចូលទៅកាន់សាលា ផ្ទះ មជ្ឈមណ្ឌលក្រុង និងកន្លែងពេញនិយមនានាដទៃផ្សេងទៀត។ រថភ្លើង V/Line និងរថយន្តក្រុងធ្វើឱ្យការធ្វើដំណើររបស់អ្នកតភ្ជាប់រវាងក្រុងមែលប៊ិននិងតំបន់ជុំវិញរដ្ឋវិចតូរីយ៉ាមានភាពងាយស្រួល។ អ្នកក៏អាចធ្វើដំណើរ ដោយថ្មើជើង ជិះកង់ ឬ ធ្វើដំណើរតាមរថយន្តរបស់ក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយបានផងដែរ។

### ជិះតាមចិត្តចង់ជុំវិញក្រុង

អ្នកអាចប្រើប្រាស់បណ្ដាញដ៏ទូលំទូលាយនៃផ្លូវកង់ផ្ដាច់មុខប្រកបដោយសុវត្ថិភាពនៅពេលអ្នកកំពុងរស់នៅក្នុងរដ្ឋវិចតូរីយ៉ា។ រួមនិងភ្ជាប់ការធ្វើដំណើរតាមរថភ្លើងជាមួយនឹងកង់ – អ្នកអាចយកកង់របស់អ្នកឡើងលើរថភ្លើងបាន។ ដោយគ្រាន់តែត្រូវប្រាកដថា អ្នកពាក់មួកសុវត្ថិភាពជានិច្ចព្បិតវាជាការតម្រូវដោយច្បាប់នៅក្នុងប្រទេសអូស្ត្រាលី។

### ត្រាំដ៏ល្បីល្បាញរបស់យើង

ត្រាំរបស់ក្រុងមែលប៊ិនជាផ្នែកមួយនៃលក្ខណៈឯករបស់ទីក្រុង។ ពួកវាជាមធ្យោបាយធ្វើដំណើរដ៏អស្ចារ្យ ដើម្បីស្វែងយល់ពីតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្មនិងតំបន់ជាយក្រុងទាំងឡាយនៅជុំវិញនោះ។ យើងមានបណ្ដាញត្រាំធំបំផុតទូទាំងពិភពលោក ដោយមានត្រាំចំនួន 500គ្រឿង និងផ្លូវចំនួន 25 ខ្សែផ្សេងៗគ្នា។ ពួកគេអាចធ្វើដំណើរស្របតាមបណ្ដោយផ្លូវដ៏ធំៗស្ទើរតែទាំងអស់របស់ក្រុង ហើយផ្លូវរបស់គេត្រូវបានពង្រីកចេញទៅកាន់តំបន់ជាយក្រុងថែមទៀត។

ត្រាំបេតិកភណ្ឌធ្វើដំណើរតាមផ្លូវរង្វង់ក្រុងដោយឥតគិតថ្លៃ ជាពិសេសសម្រាប់ ឱ្យភ្ញៀវទេសចរមកលេងក្រុងមែលប៊ិន។ ត្រាំធ្វើដំណើរតាមផ្លូវធំៗជាច្រើនចូលទៅក្នុងតំបន់ជាយក្រុង ប៉ុន្តែមានតែត្រាំមួយចំនួនទេ ដែលធ្វើដំណើរចេញចូលដល់តំបន់កណ្ដាលជាយក្រុងនិងចេញក្រៅតំបន់ជាយក្រុង។

### បណ្ដាញរថភ្លើងកណ្ដាលក្រុង

ក្រុងមានប្រព័ន្ធរថភ្លើងកណ្ដាលក្រុង (ហៅថាចំណុចកណ្ដាលក្រុង) ដែលមានមួយផ្នែកស្ថិតនៅក្រោមដី។ មានស្ថានីយ៍ប្រាំនៅក្នុងមជ្ឈមណ្ឌលក្រុង៖ Flinders Street, Parliament, Melbourne Central, Flagstaff and Southern Cross

មានរថភ្លើង 16 ខ្សែផ្សេងគ្នាចេញទៅតំបន់ក្រៅជាយក្រុង។ រថភ្លើងចាប់ផ្ដើមដំណើរការប្រហែលម៉ោង 5ព្រឹក រហូតដល់រំលងអាធ្រាត្រសម្រាប់ខ្សែភាគច្រើន។ នៅយប់ថ្ងៃសុក្រនិងថ្ងៃសៅរ៍ រថភ្លើងនិងត្រាំមួយចំនួនដំណើរការពេញមួយយប់។

### រថភ្លើងតាមតំបន់ឆ្ពោះមកកាន់រដ្ឋវិចតូរីយ៉ា

V/Line គឺជាបណ្ដាញផ្លូវដែកថ្នាក់តំបន់របស់រដ្ឋវិចតូរីយ៉ា។ វានឹងដឹកអ្នកទៅកាន់តំបន់ទេសចរណ៍សំខាន់ៗនៅទូទាំងរដ្ឋ។ វាភ្ជាប់ទៅកាន់តំបន់ក្រុងនានាក្នុងរដ្ឋវិចតូរីយ៉ា និងទៅកាន់រដ្ឋអូស្ត្រាលីផ្សេងទៀតផងដែរ។

### តើធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរសាធារណៈដោយរបៀបណា

ដើម្បីធ្វើដំណើរនៅក្នុងរដ្ឋវិចតូរីយ៉ា អ្នកនឹងចាំបាច់ត្រូវទិញប័ណ្ណ myki ឬ Child myki។ ប័ណ្ណនេះនឹងអាចឱ្យអ្នកធ្វើដំណើរតាមរថយន្តក្រុង រថភ្លើង និងសេវារថយន្តអគ្គិសនីបាន។ ប្រព័ន្ធប័ណ្ណ myki អនុញ្ញាតឱ្យអ្នកបញ្ចូលទឹកប្រាក់បន្ថែមបានយ៉ាងងាយស្រួលទៅក្នុងប័ណ្ណ myki របស់អ្នក នៅតាមស្ថានីយ៍រថភ្លើង ហាងលក់កាសែត-ទស្សនាវដ្ដី និងហាងលក់ទំនិញភាគច្រើន។ អ្នកក៏អាចបង្កើតគណនីដើម្បីបង់ប្រាក់អនឡាញ ហើយ 'ចុចលើទូរស័ព្ទ' ដើម្បីធ្វើដំណើរដោយប្រើកម្មវិធី app នៅលើទូរស័ព្ទរបស់អ្នកជំនួសឱ្យការប្រើប័ណ្ណជាក់ស្ដែង។

អ្វីដែលសំខាន់ អ្នកត្រូវចាំថានៅក្នុងក្រុងមែលប៊ិន បណ្ដាញមធ្យោបាយធ្វើដំណើរសាធារណៈត្រូវបានបែងចែកជាពីរតំបន់អាស្រ័យទៅលើចម្ងាយផ្លូវពីមជ្ឈមណ្ឌលក្រុង។ តម្លៃការធ្វើដំណើររបស់អ្នកនឹងអាស្រ័យទៅលើ៖

- តំបន់មួយឬច្រើន ដែលអ្នកចង់ធ្វើដំណើរទៅកាន់
- រយៈពេលសម្រាប់សំបុត្ររបស់អ្នក (ពីរម៉ោង ប្រចាំថ្ងៃ ប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំឆ្នាំ)។

អ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈទាំងអស់ដែលមានអាយុចាប់ពី 5 ដល់ 18ឆ្នាំ (ក្រោម 19ឆ្នាំ) អាចទិញប័ណ្ណ Child myki បាន ហើយអាចបង់ថ្លៃក្នុងតម្លៃទាប។

ករណីនេះ អនុវត្តបានតែចំពោះអ្នកដែលមានអាយុ 18ឆ្នាំនិងទាបជាង ដោយរួមបញ្ចូលទាំងសិស្សនិងអ្នកទេសចរអន្តរជាតិ ដែលមានន័យថាពួកគេអាចបង្ហាញថាពួកគេមានអាយុ 18ឆ្នាំ ឬក្រោមនេះ។

អតិថិជនដែលមានអាយុ 17 និង 18ឆ្នាំ ត្រូវយកតាមនូវប័ណ្ណបញ្ជាក់ពីអាយុ ដែលចេញដោយរដ្ឋាភិបាល (ដូចជា ប័ណ្ណបើកបររដ្ឋវិចតូរីយ៉ា ប័ណ្ណអនុញ្ញាតអ្នកសិក្សាច្បាប់បើកបរ ប័ណ្ណបញ្ជាក់ពីអាយុ ឬលិខិតឆ្លងដែនជាដើម) ឬ ភ័ស្តុតាងបញ្ជាក់ពីការមានសិទ្ធិទទួលបានការបញ្ចុះតម្លៃផ្សេងទៀត (ដូចជាប័ណ្ណសម្គាល់ខ្លួនសិស្ស PTV) នៅគ្រប់ពេលទាំងអស់ដែលអ្នកធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរសាធារណៈ។ មិនចាំបាច់មានភ័ស្តុតាងបញ្ជាក់ឡើយសម្រាប់ក្មេងអាយុ 16ឆ្នាំនិងក្រោមនេះ។

សម្រាប់ព័ត៌មានបន្ថែមសូមមើល៖ ptv.vic.gov.au/tickets/myki/concessions-and-free-travel/children-and-students/children





# ការសិក្សានិងការរស់នៅក្នុងរដ្ឋវិចតូរីយ៉ា

អ្នកប្រហែលជាបានធ្វើការស្រាវជ្រាវរួចហើយពីអត្ថប្រយោជន៍ជាច្រើននៃការសិក្សានៅក្នុងរដ្ឋវិចតូរីយ៉ា។ នៅក្នុងផ្នែកនេះនឹងផ្តល់ដល់អ្នកជាគំនិត ថាតើក្នុងភាពជាសិស្សនៅទីនេះមានលក្ខណៈយ៉ាងដូចម្តេច? អ្នកក៏នឹងអាចរកព័ត៌មានបន្ថែមទៀតបានផងដែរស្តីអំពីប្រធានបទទាំងនេះតាម៖ **study.vic.gov.au/en/study-in-victoria/pages/default.aspx**

## ប្រព័ន្ធសាលារៀនរដ្ឋវិចតូរីយ៉ា

ប្រព័ន្ធសាលារៀនរដ្ឋវិចតូរីយ៉ាល្បីល្បាញខាងកម្មវិធីសិក្សាសម្បូរបែប លោកគ្រូអ្នកគ្រូមានការប្តេជ្ញាចិត្តខ្ពស់ និងជួយបញ្ចេញនូវភាពអស្ចារ្យដែលអ្នកគ្រប់ៗគ្នាមាន។ សាលារបស់អ្នកនឹងរក្សានូវទំនាក់ទំនងជាទៀងទាត់ជាមួយនឹងឪពុកម្តាយរបស់អ្នក ដូច្នេះហើយពួកគេនឹងដឹងអំពីវឌ្ឍនភាពសិក្សារបស់អ្នក។

### កន្លែងសិក្សា

បន្ទប់រៀនគឺមាននៅគ្រប់ទីកន្លែងទាំងអស់ឱ្យតែគ្រូយល់ថាសមស្របបំផុតសម្រាប់ការសិក្សារបស់សិស្ស។ជាទូទៅសិស្សប្តូរចុះឡើងពីបន្ទប់សិក្សាមួយទៅមួយជាជាងការស្ថិតនៅក្នុងបន្ទប់តែមួយរហូត។ អ្នកអាចនឹងមើលឃើញថាគ្រូប្រើប្រាស់នូវកន្លែងសិក្សាផ្សេងៗសូម្បីតែនៅតាមឧទ្យាន សួនសត្វ សារមន្ទីរឬសារមន្ទីររូបថតក៏មានដែរ។ អ្នកនឹងរៀនដោយឯករាជ្យ និងក្នុងស្ថានភាពជាក្រុមសិក្សាទាំងនៅក្នុងថ្នាក់រៀននិងក្រៅម៉ោងសិក្សាក្នុងថ្នាក់ (ឧ.ទា. កិច្ចការសាលានិងការសិក្សាត្រៀមប្រឡង)។

ការបង្រៀនតាមថ្នាក់មានលក្ខណៈរស់រវើកនិងគួរឱ្យរំភើប ហើយអ្នកនឹងដឹងខ្លួនថា អ្នករៀនតាមមធ្យោបាយខុសៗគ្នាជាច្រើន។ នៅក្នុងថ្នាក់រៀនអ្នកនឹងមានឱកាសចូលរួមការពិភាក្សាគ្នាដោយរស់រវើក សួរសំណួរជាច្រើន និងពេញចិត្តចំពោះការគាំទ្រជាវិជ្ជមានពីអ្នកដទៃ។

### កម្មវិធីអប់រំនិងការវាយតម្លៃ

នៅក្នុងរដ្ឋវិចតូរីយ៉ា មុខវិជ្ជាសិក្សារបស់អ្នកត្រូវបានបង្រៀនអាស្រ័យទៅតាមឆ្នាំសិក្សារបស់សាលា។ ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី10 អ្នកនឹងរៀនតាមកម្មវិធីសិក្សារដ្ឋវិចតូរីយ៉ា F-10។ សិស្សានុសិស្សនៅក្នុងថ្នាក់ទី11 និងថ្នាក់ទី12 សិក្សាសម្រាប់វិញ្ញាបនបត្រអប់រំរដ្ឋវិចតូរីយ៉ា (VCE)។ ការវាយតម្លៃតាមដានពីវឌ្ឍនភាពសិក្សារបស់អ្នកធ្វើឡើងពេញមួយឆ្នាំ ដោយការប្រឡងនៅពេលបញ្ចប់ថ្នាក់ទី10 ទី11 និងទី12។ សាលារបស់អ្នកក៏នឹងផ្តល់ដល់អ្នកផងដែរនូវជម្រើសមួយនៃសកម្មភាពសិក្សាក្រៅថ្នាក់និង បទពិសោធន៍ដូចជាទស្សនកិច្ចសិក្សានិងសកម្មភាពកីឡា និង តូរ្យតន្ត្រីជាដើម។ អ្នកចាំបាច់ត្រូវតែចូលរួមក្នុងសកម្មភាពទាំងនេះដោយហេតុថានេះជាមធ្យោបាយដ៏ប្រសើរបំផុតដើម្បីបង្កើតមិត្តភក្តិនិងបង្កើនសមត្ថភាពក្នុងការនិយាយភាសាអង់គ្លេសនិងទំនុកចិត្តរបស់អ្នក។

### សិស្សនិងគ្រូ

អ្នកអាចនឹងយល់ថាថ្នាក់រៀននៅរដ្ឋវិចតូរីយ៉ាសម្រាកច្រើនជាងសាលាចុងក្រោយរបស់អ្នក។ ទោះបីជាគ្រូរបស់អ្នកនឹងរួសរាយរាក់ទាក់និងអាចទាក់ទងបាន។ ទំនាក់ទំនងរវាងសិស្សនិងគ្រូនៅតែផ្អែកលើការគោរព។ អ្នកនឹងហៅគ្រូតាមនាមត្រកូល (ឧ.លោកស្រី លោក អ្នកស្រីចន) ពេលគ្រូរបស់អ្នកនឹងហៅអ្នកតាមនាមខ្លួនរបស់អ្នក។គ្រូរបស់អ្នកនឹងផ្តល់នូវការគាំពារជម្រញនិងលើកទឹកចិត្តដល់អ្នក។ ពួកគេងាយស្រួលជួបជជែកជាមួយ និងដោយការគោរព។ គ្រូនឹងជួយជានិច្ចនៅពេលអ្នកមានអ្វីមួយដែលមិនយល់។ អ្នកសម្របសម្រួលសិស្សអន្តរជាតិរបស់អ្នកនឹងផ្តល់នូវការគាំទ្រដែលអ្នកត្រូវការបន្ថែមទៀតទាំងជីវិតសិក្សា និងការរស់នៅក្នុងផ្ទះ។

### របាយការណ៍ពីវឌ្ឍនភាពសិក្សារបស់អ្នក

សាលាភាគច្រើនអញ្ជើញឪពុកម្តាយដែលរស់នៅក្នុងប្រទេសអូស្ត្រាលីឱ្យចូលរួមក្នុងកម្មវិធីជួបសម្ភាសរវាងឪពុកម្តាយនិងគ្រូយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ ប្រសិនបើឪពុកម្តាយរបស់អ្នករស់នៅក្រៅប្រទេសអូស្ត្រាលី សាលារបស់អ្នកអាចនឹងរៀបចំការសម្ភាសតាមទូរស័ព្ទ ហើយអ្នកសម្របសម្រួលសិស្សអន្តរជាតិ (ISC) មួយចំនួនក៏អាចធ្វើដំណើរទៅជួបឪពុកម្តាយសិស្សនៅឯបរទេសផងដែរ។ ឪពុកម្តាយក៏អាចស្នើសុំរបាយការណ៍សាលាដែលបានបកប្រែជាលាយលក្ខណ៍អក្សរផងដែរ។

ISC របស់អ្នកគឺជាមនុស្សដែលក្រុមគ្រួសាររបស់អ្នកគួរតែមានទំនាក់ទំនងមុនគេ។ ឪពុកម្តាយរបស់អ្នកអាចហៅទូរស័ព្ទមកសាលារបស់អ្នកនៅពេលណាក៏បានដើម្បីនិយាយជាមួយពួកគេ។ ផ្នែកអប់រំអន្តរជាតិ ក៏អាចទំនាក់ទំនងបានផងដែរតាមរយៈអ៊ីមែល international@education.vic.gov.au។

### ថ្ងៃសិក្សាទូទៅ

| | |
|---|---|
| 8:30 ព្រឹក | ថ្នាក់ចាប់ផ្តើម |
| 8:30 ព្រឹក–9:25 ព្រឹក | ម៉ោងបង្រៀនទី 1 |
| 9:25 ព្រឹក–10:15 ព្រឹក | ម៉ោងបង្រៀនទី 2 |
| 10:15 ព្រឹក–10:45 ព្រឹក | សម្រាក |
| 10:45 ព្រឹក–11:35 ព្រឹក | ម៉ោងបង្រៀនទី 3 |
| 11:35 ព្រឹក–12:20 ថ្ងៃត្រង់ | ម៉ោងបង្រៀនទី 4 |
| 12:20 ថ្ងៃត្រង់–1:20 រសៀល | អាហារថ្ងៃត្រង់ |
| 1:20 រសៀល–2:10 រសៀល | ម៉ោងបង្រៀនទី 5 |
| 2:10 រសៀល–3:00 រសៀល | ម៉ោងបង្រៀនទី 6 |
| 3:00 រសៀល | ម៉ោងសិក្សាជំនួយឬពេលវេលានៅផ្ទះ ម៉ោងសម្រាកទៅផ្ទះ |

# ការថែរក្សាសុខភាពរបស់អ្នក

**នៅពេលអ្នកស្ថិតនៅឆ្ងាយពីប្រទេសកំណើតរបស់អ្នកអ្វីដែលសំខាន់គឺអ្នកត្រូវមើលថែទាំសុខភាពនិងសុខុមាលភាពរបស់អ្នកឱ្យបានល្អ។ នេះរួមទាំងសុខភាពរាងកាយ សុខភាពផ្លូវចិត្ត និងអនាម័យផ្ទាល់ខ្លួន។**

## សុខភាពរាងកាយ

ផ្តល់អាទិភាពដល់សុខភាពរាងកាយដោយធ្វើយ៉ាងណាឱ្យរាងកាយមានលក្ខណៈសកម្មជានិច្ចពេញមួយរយៈពេលនៃបទពិសោធន៍ស្នាក់នៅរបស់អ្នកជាមួយនឹងក្រុមគ្រួសារអូស្ត្រាលី។

គន្លឹះសម្រាប់រក្សារាងកាយឱ្យបានសមសួន៖

**រក្សារាងកាយឱ្យសកម្ម៖** គិតដល់ការដើរ ឬ ជិះកង់តាមផ្លូវកង់ដ៏មានសុវត្ថិភាពជាច្រើនរបស់យើងជំនួសឱ្យការប្រើមធ្យោបាយធ្វើដំណើរសាធារណៈនៅពេលអាចធ្វើបាន ឬ ចេញរត់ហាត់ប្រាណនៅពេលអ្នកទំនេរ។ ពិភាក្សាជាមួយនឹងគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅ ជាមួយ ឬ សាលារបស់អ្នកអំពីកន្លែងដែលមានសុវត្ថិភាពបំផុតដើម្បីរក្សារាងកាយរបស់អ្នកឱ្យសកម្ម។

**ជ្រើសរើសជម្រើសអាហារវិជ្ជមាន៖** បន្លែនិងផ្លែឈើស្រស់ធ្វើជាអាហារសម្រន់ដ៏ប្រសើរ និងអាចជួយបង្កើនសុខភាពផ្លូវចិត្តនិងរាងកាយរបស់អ្នក។ ញាំអាហារមានសុខភាពក៏នឹងជួយផ្តល់ថាមពលដល់អ្នកឱ្យផ្តោតលើការសិក្សារបស់អ្នក។

**ចូលរួមសកម្មភាពកីឡាក្នុងសាលា៖** ធ្វើបែបនេះក៏ជាមធ្យោបាយដ៏អស្ចារ្យមួយដើម្បីរៀនអំពីវប្បធម៌អូស្ត្រាលីនិងបង្កើតមិត្តថ្មីៗបានមួយចំនួនដែរ។ សាលាមធ្យមសិក្សារដ្ឋវិចតូរីយ៉ាផ្តល់នូវសកម្មភាពកីឡានិងការប្រកួតជាច្រើនផ្សេងៗគ្នា រាប់ចាប់តាំងពីហ្គេមជម្រុញការទំនាក់ទំនងសង្គមនៅពេលញ៉ាំអាហារថ្ងៃត្រង់ រហូតដល់ការប្រកួតជាមួយនឹងសាលាផ្សេងៗទៀត។

ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលខ្លួនសូមប្រាប់ដល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយនិងអ្នកសម្របសម្រួលសិស្សអន្តរជាតិរបស់អ្នក និងចាត់ចែងទៅជួបគ្រូពេទ្យ (សូមមើលផ្នែក 'ការជួបជាមួយគ្រូពេទ្យ' សម្រាប់ព័ត៌មានលម្អិត)។

## សុខភាពផ្លូវចិត្ត

ការរស់នៅឆ្ងាយពីក្រុមគ្រួសារនិងមិត្តជិតស្និទ្ធ ការទម្លាប់ខ្លួនទៅនឹងវប្បធម៌ថ្មី និងការរក្សាការសិក្សាឱ្យទាន់នោះអាចមានភាពតឹងតែងខ្លាំងណាស់។

គន្លឹះសំខាន់ដើម្បីរក្សាសុខភាពផ្លូវចិត្តឱ្យបានល្អ៖

- អនុវត្តការធ្វើសមាធិជាប្រចាំ ឬ សាកល្បងធ្វើយោហ្គា។
- ការធ្វើលំហាត់ប្រាណឱ្យបានទៀងទាត់ដោយការលេងកីឡា ឬ ការប្រើប្រាស់មជ្ឈមណ្ឌលហ្វឹកហាត់កីឡារបស់សាលា ឬរបស់ក្រុមប្រឹក្សាក្នុងមូលដ្ឋានអ្នក។
- កុំប្រឹងប្រែងហួសពេក៖ សម្រាកពីការសិក្សាឱ្យបានទៀងទាត់ ជាពិសេសនៅពេលកំពុងត្រៀមសម្រាប់ការប្រឡង។
- ចាំបាច់អ្នកត្រូវគេងឱ្យបានគ្រប់គ្រាន់នៅពេលយប់ យ៉ាងហោចណាស់ប្រាំបីម៉ោងឱ្យបានញឹកញាប់តាមដែលអាចធ្វើបាន។
- ចំណាយពេលដើម្បីញ៉ាំអាហារផ្តល់សុខភាពនិងឱ្យបានទៀងទាត់។
- ប្រើពេលដើម្បីធ្វើអ្វីដែលធ្វើឱ្យអ្នកសប្បាយចិត្ត ដូចជាដើរលេងជាមួយមិត្តភក្តិ ទៅមើលភាពយន្ត ឬចូលរួមក្នុងសកម្មភាពសិក្សាក្រៅថ្នាក់នានារបស់សាលា។

## ការស្វែងរកជំនួយ

ប្រសិនបើអ្នកពិតជាមានការព្រួយបារម្ភពីសុខភាពផ្លូវចិត្តមែននោះ អ្វីដែលសំខាន់គឺអ្នកត្រូវតែពិភាក្សាជាមួយនឹងនរណាម្នាក់ដែលអ្នកទុកចិត្ត។ សូមទាក់ទង ISC របស់អ្នក, ពិភាក្សាជាមួយនឹងក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយ ឬជួបជាមួយនឹងអ្នកអាជីពផ្នែកសុខភាពផ្លូវចិត្ត (សូមមើលទៅផ្នែកការជួបគ្រូពេទ្យ' សម្រាប់ព័ត៌មានលម្អិតបន្ថែម)។

**ចូរចងចាំថា ISC របស់អ្នកនឹងជួយដល់អ្នកជានិច្ច។ អ្នកអាចទាក់ទងពួកគេបាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។**

ទាំងនេះជាអង្គការសុខភាពផ្លូវចិត្តមួយចំនួនដែលអ្នកអាចទាក់ទងបាន៖

### អង្គការ eHeadspace

គេហទំព័រដែលយុវជនអាចទទួលបានព័ត៌មានទូទៅពីបញ្ហាផ្លូវចិត្ត ឬ និយាយដោយមានការរក្សាការសម្ងាត់ជាមួយនឹងអ្នកអាជីពផ្នែកសុខភាពផ្លូវចិត្តយុវវ័យ។

| គេហទំព័រ៖ | headspace.org.au/eheadspace |
|---|---|

### អង្គការជំនួយកុមារតាមខ្សែទូរសព្ទ (Kids Helpline)

ផ្តល់សេវាតាមទូរសព្ទ 24ម៉ោង ដែលអ្នកអាចនិយាយបានដោយរក្សាការសម្ងាត់ជាមួយនឹងអ្នកផ្តល់ប្រឹក្សានិងរកមើលសេវាសុខភាពផ្លូវចិត្តនៅក្នុងមូលដ្ឋានរបស់អ្នក។

| ទូរសព្ទ៖ | 1800 55 1800 |
|---|---|

## អនាម័យផ្ទាល់ខ្លួន

សុខភាពល្អមានន័យថាមានអនាម័យល្អ។ លាងដៃឱ្យបានស្អាតនឹងជួយអ្នកឱ្យជៀសផុតពីជំងឺបាន។ លាងដៃរបស់អ្នកមុនពេលញ៉ាំអាហារ និងក្រោយពេលចេញពីបង្គន់ ឬនៅពេលអ្នកក្អក ឬ កណ្តាស់ក្នុងករណីមានជំងឺផ្តាសាយ ឬ គ្រុនក្តៅ។

ចូរកុំភ្លេចងូតទឹកឱ្យបានយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ អាកាសធាតុប្រទេសអូស្ត្រាលីក្តៅដូច្នេះការងូតទឹក ស្លៀកសម្លៀកបំពាក់មានអនាម័យ និងការប្រើប្រាស់គ្រឿង បំបាត់ក្លិនខ្លួនមានគុណភាពល្អមានសារៈសំខាន់ណាស់។

ផលិតផលអនាម័យសម្រាប់ស្ត្រីត្រូវបានផ្តល់ដោយមិនគិតថ្លៃនៅតាមសាលារដ្ឋវិចតូរីយ៉ាទាំងអស់ ហើយក៏អាចរកទិញបានដោយងាយពីគ្រប់ហាងទំនើបធំៗ ឬឱសថស្ថានទាំងអស់។ ផលិតផលទាំងនេះអាចនឹងមានលក្ខណៈខុសគ្នាពីប្រទេសកំណើតរបស់អ្នក។ ឧទាហរណ៍នៅក្នុងប្រទេសអូស្ត្រាលី ដុំសំឡីអនាម័យសម្រាប់ស្ត្រីមិនមានផ្តល់ដោយភ្ជាប់ជាមួយនឹងបំពង់រុញដុំសំឡីបញ្ចូលទេ។ ប្រសិនបើអ្នកមានការព្រួយបារម្ភពីការរកផលិតផលអនាម័យសមស្របនោះ សូមពិភាក្សាជាមួយនឹងក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ ឬ ISC របស់អ្នក។

ផលិតផលអនាម័យមាត់ធ្មេញក៏មានសារៈសំខាន់ផងដែរ ហើយវានឹងជួយអ្នកឱ្យជៀសផុតពីការពុកធ្មេញ។ កុំភ្លេចដុសធ្មេញរបស់អ្នកពេលព្រឹកនិងល្ងាច ព្រមទាំងទាក់វាផងដែរ។ ទៅជួបពេទ្យធ្មេញរៀងរាល់ 6 ខែម្តងនឹងជួយការពារដល់ការបំផ្លាញ នានាក្នុងរយៈពេលវែងបាន។

## ការជួបគ្រូពេទ្យ៖ របៀបណាត់ជួបគ្រូពេទ្យ

ដើម្បីធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិតណាម្នាក់ អ្នកនឹងត្រូវការព័ត៌មានអំពីការធានារ៉ាប់រងការថែទាំសុខភាពសិស្សបរទេសរបស់អ្នក ដែលហៅកាត់ជារឿយៗថា "OSHC"។

នៅពេលអ្នកបានចុះឈ្មោះជាមួយយើង អ្នកមានជម្រើសចំនួនពីរសម្រាប់ការរៀបចំ OSHC។ ជម្រើសទាំងនោះមាន៖

ជម្រើសទី 1៖ ឪពុកម្តាយ/អាណាព្យាបាលស្របច្បាប់ ឬទីភ្នាក់ងារអប់រំដែលបានចាត់តាំងដើម្បីជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងការថែទាំសុខភាពសិស្សរបស់អ្នក។

ជម្រើសទី 2៖ ឪពុកម្តាយ/អាណាព្យាបាលស្របច្បាប់ ឬទីភ្នាក់ងារអប់រំ បានសុំឱ្យក្រសួងអប់រំរៀបចំ OSHC ជំនួយមុខអ្នក។

ប្រសិនបើអ្នកជ្រើសយកជម្រើសទី 1 ឪពុកម្តាយ/អាណាព្យាបាលស្របច្បាប់របស់អ្នក ឬទីភ្នាក់ងារអប់រំនឹងទទួលបានព័ត៌មាន OSHC។ សូមប្រាកដថាអ្នកនាំយកព័ត៌មាននេះតាមខ្លួនអ្នក នៅពេលអ្នកធ្វើដំណើរទៅកាន់ប្រទេសអូស្ត្រាលី។

ប្រសិនបើអ្នកជ្រើសយកជម្រើសទី 2 នោះ ISC របស់អ្នកនឹងជួយអ្នកឱ្យទទួលបានព័ត៌មាននេះនៅពេលអ្នកមកដល់សាលារៀនរបស់អ្នក។

នៅពេលអ្នកកក់ការណាត់ជួប អ្នកអាចស្នើសុំវេជ្ជបណ្ឌិតតាមការចង់បាន ឬភេទវេជ្ជបណ្ឌិត។ ហើយក៏អាចស្វែងរកវេជ្ជបណ្ឌិតដែលនិយាយភាសាកំណើតរបស់អ្នកផងដែរ។ សូមទាក់ទងទៅកាន់ ISC របស់អ្នក ឬគ្រួសារដែលអ្នកស្នាក់នៅជាមួយ ដើម្បីជួយអ្នកក្នុងការស្វែងរកវេជ្ជបណ្ឌិតដែលសមស្របតាមតម្រូវការរបស់អ្នក។ សាលារៀនខ្លះមានទាំងវេជ្ជបណ្ឌិតដែលមកកាន់សាលារៀនម្តងក្នុងមួយសប្តាហ៍ និងផ្តល់សេវាដោយឥតគិតថ្លៃសម្រាប់សិស្សទៀតផង។

វេជ្ជបណ្ឌិតរបស់អ្នក ក៏អាចជួយអ្នកនៅលើក្តីកង្វល់សុខភាពផ្លូវចិត្តផងដែរ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីសុខភាពរាងកាយនិងសុខភាពផ្លូវចិត្ត អ្នកអាចនឹងសាករកមើលនៅលើគេហទំព័រដ៏មានប្រយោជន៍នេះបាន៖ youthcentral.vic.gov.au/advice-for-life/health



# សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នក

អ្វីដែលសំខាន់នោះគឺថា អ្នកត្រូវដឹងពីសិទ្ធិនិងការទទួលខុសត្រូវរបស់អ្នក។ អ្នកមានសិទ្ធិជាសិស្សនិងជាពលរដ្ឋស្នាក់នៅបណ្ដោះអាសន្នក្នុងប្រទេសអូស្ត្រាលីដែលមានបំណងការពារដល់អ្នក។ អ្នកក៏មានការទទួលខុសត្រូវច្រើនក្នុងខណៈពេលដែលកំពុងសិក្សានិងរស់នៅក្នុងប្រទេសអូស្ត្រាលីដែលអាចនឹងខុសពីនៅក្នុងប្រទេសកំណើតរបស់អ្នក។

ខាងក្រោមនេះជាចំណុចមួយចំនួនត្រូវពិចារណាដែលនឹងជួយការពារអ្នកនិងអ្នកដែលនៅជុំវិញខ្លួនអ្នក។

## សុវត្ថិភាពកុមារ

អ្នកអាចរំពឹងបានថា វានឹងមានសុវត្ថិភាព និង ទទួលអារម្មណ៍ថាមានសុវត្ថិភាពនៅគ្រប់ទីកន្លែងដែលអ្នកទៅនិងអ្វីៗដែលអ្នកធ្វើ។ អ្នកអាចរំពឹងបានថា មនុស្សពេញវ័យនៅសាលារបស់អ្នកដឹងពីរបៀបរក្សាឱ្យអ្នកមានសុវត្ថិភាពបាន។

ក្រសួងអប់រំនិងបណ្ដុះបណ្ដាល និង សាលារដ្ឋវិចតូរីយ៉ាប្ដេជ្ញារក្សាសុវត្ថិភាពនិងសុខុមាលភាពរបស់កុមារនិងយុវជនឱ្យបាន។ យើងបង្ហាញនូវការប្ដេជ្ញាចិត្តនេះដោយផ្ដល់នូវព័ត៌មានការគាំពារនិងដំណើរការនានាទៅដល់សិស្សានុសិស្ស បុគ្គលិក និងក្រុមគ្រួសារអូស្ត្រាលីដែលផ្ដល់នូវការស្នាក់នៅតាមផ្ទះដល់សិស្សានុសិស្សរបស់យើងនូវសុវត្ថិភាពនិងសុខុមាលភាព និងដើម្បីជួយបង្កើតបរិយាកាសសុវត្ថិភាពស្របទៅតាមសារតាខុសៗគ្នារបស់ពួកគេ។

ប្រសិនបើអ្នកយល់ថាមិនមានសុវត្ថិភាព ឬ មាននរណាកំពុងធ្វើឱ្យអ្នកមិនមានភាពកក់ក្ដៅ ឬមិនសប្បាយចិត្ត ឬអ្នកយល់ថាមានអ្វីមួយមិនត្រឹមត្រូវនោះសាលារបស់អ្នកត្រូវបានតម្រូវឱ្យការពារដល់អ្នក។ សូមទាក់ទងទៅកាន់ ISC របស់អ្នក លោកគ្រូ នាយកសាលា ឬ គ្រួសារអូស្ត្រាលីដែលផ្ដល់ការស្នាក់នៅឱ្យបានឆាប់តាមដែលអាចធ្វើបាន។ ពួកគេនឹងយកចិត្តទុកដាក់ស្ដាប់ពីការព្រួយបារម្ភរបស់អ្នក ហើយតម្រូវឱ្យគេចាត់វិធានការស្របទៅតាមច្បាប់។

## ការសម្លុតធ្វើបាប

សាលាវិចតូរីយ៉ាមានបរិយាកាសស្រស់ស្រាយដែលតម្រូវឱ្យមានអាកប្បកិរិយាប្រកបដោយការគោរព ការផ្ដល់ជាគំរូ និងការលើកទឹកចិត្ត។ គ្រប់សាលាវិចតូរីយ៉ាទាំងអស់មានគោលនយោបាយមិនអត់អោនចំពោះការសម្លុតធ្វើបាបឡើយ។

ការសម្លុតធ្វើបាបអាចជាឥរិយាបថគ្រោះថ្នាក់ ឬគគ្លើន។ វាអាចមានទម្រង់ជាការសម្លុតធ្វើបាបទៅលើអារម្មណ៍ រាងកាយ ឬ តាមអនឡាញ ដែលច្រើនត្រូវបានគេហៅថាជាការសម្លុតធ្វើបាបតាមអ៊ីនធើណិត។

### អ្វីដែលអ្នកត្រូវធ្វើក្នុងករណីដែលអ្នក ឬនរណាម្នាក់នៅជុំវិញអ្នកកំពុងត្រូវបានគេសម្លុតធ្វើបាប

ប្រសិនបើអ្នកត្រូវបានគេសម្លុតធ្វើបាបនៅសាលា អ្វីដែលសំខាន់នោះគឺត្រូវពិភាក្សាជាមួយនឹង ISC របស់អ្នក លោកគ្រូអ្នកគ្រូ នាយកសាលា ឬគ្រួសារផ្ដល់ការស្នាក់នៅតាមផ្ទះ ដែលនឹងជួយចាត់ចែងបញ្ហានេះ។ សាលារបស់អ្នកដឹងពីរបៀបជួយដល់អ្នក ហើយបុគ្គលិកនៅទីនោះមានតួនាទីមើលថែសុខុមាលភាពរបស់អ្នក និងធានាថាអ្នកមានសុវត្ថិភាព។

### អ្នកបញ្ឈប់ការសម្លុតធ្វើបាប (Bully Stoppers)

អ្នកបញ្ឈប់ការសម្លុតធ្វើបាបគឺជាគេហទំព័រដែលអ្នកអាចទទួលបានព័ត៌មានបន្ថែម ឬ រកនរណាម្នាក់ដើម្បីពិភាក្សាដោយរក្សាការសម្ងាត់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ **https://www.vic.gov.au/bully-stoppersx**

## បទបញ្ជាផ្ទៃក្នុងសាលា

គ្រប់សាលាទាំងអស់មានបទបញ្ជាផ្ទៃក្នុងផ្សេងៗគ្នា ដើម្បីជួយធានាដល់សុភមង្គលសុវត្ថិភាព និងសុខុមាលភាពដល់សិស្សនិងបុគ្គលិកទាំងអស់គ្នា។ ISC របស់អ្នកនឹងផ្ដល់ដល់អ្នកនូវបទបញ្ជាផ្ទៃក្នុងនៅពេលអ្នកមកដល់។ អ្វីដែលសំខាន់គឺត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងទាំងនេះដើម្បីឱ្យម្នាក់ៗអាចទទួលបាននូវបទពិសោធអប់រំមួយមានលក្ខណៈល្អប្រសើរ។

## គ្រឿងញៀនិងគ្រឿងស្រវឹង

នៅពេលអ្នកនៅឆ្ងាយពីផ្ទះ អ្វីដែលនៅតែមានសារៈសំខាន់នោះគឺត្រូវប្រព្រឹត្តិឱ្យបានសមរម្យអាចទទួលយកបាន។ ចូរចាំថា ការសេពគ្រឿងស្រវឹង ជក់បារី និងការលេងល្បែងស៊ីសងក្រោមអាយុ 18ឆ្នាំ ជាអំពើខុសច្បាប់នៅប្រទេសអូស្ត្រាលី និងដូចគ្នាទៅនឹងប្រទេសជាច្រើនដែរ ការប្រើប្រាស់គ្រឿងញៀនក៏ខុសច្បាប់ដែរ។

សម្រាប់ព័ត៌មានបន្ថែមស្ដីពីសិទ្ធិរបស់អ្នក សូមមើល៖ **youthcentral.vic.gov.au/advice-for-life/know-your-rights**

## សុវត្ថិភាពអ៊ីនធើណិត

សាលារៀនរបស់អ្នកនឹងផ្ដល់ជូនអ្នកនូវព័ត៌មានអំពីការប្រើប្រាស់អ៊ីនធើណិតនិងទូរស័ព្ទប្រកបដោយសុវត្ថិភាព។ សូមយល់ដឹងអំពីបទល្មើសតាមប្រព័ន្ធអ៊ីនធើណិត និងអំពើឆបោក។ ពេលខ្លះ ជនឆបោកក្លែងខ្លួនធ្វើជាមន្ត្រីរដ្ឋាភិបាល អ្នកលក់រាយ ឬអ្នកតេសំបុត្រ ឬថែមទាំងក្លែងខ្លួនជាមន្ត្រីប៉ូលីសតាមអនឡាញឬតាមទូរស័ព្ទទៀតផង។ សូមទាក់ទងទៅ ISC របស់អ្នក ឬគ្រួសារដែលអ្នកស្នាក់នៅជាមួយ ឬឪពុកម្ដាយ ប្រសិនបើអ្នកគិតថាអ្នកបានទទួលការហៅទូរស័ព្ទក្លែងក្លាយSMS/សារជាអក្សរ ឬអ៊ីមែល។ សូមប្រុងប្រយ័ត្នចំពោះការហៅទូរស័ព្ទ SMS/សារជាអក្សរ ឬអ៊ីមែល ដែលទាមទារឱ្យអ្នក៖

- បង់ប្រាក់
- ផ្ដល់ព័ត៌មានលម្អិតអំពីធនាគារ ឬព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នក។
- បញ្ចូលឈ្មោះអ្នកប្រើប្រាស់របស់អ្នក ឬពាក្យសម្ងាត់
- ចុចលើតំណភ្ជាប់។



# ការសង្គ្រោះបន្ទាន់និងស្ថានភាពដ៏គួរឱ្យព្រួយបារម្ភ

ការសង្គ្រោះបន្ទាន់អាចជាហានិភ័យដោយផ្ទាល់ចំពោះសុខភាព ជីវិត ឬ ទ្រព្យសម្បត្តិរបស់នរណាម្នាក់។ ស្ថានភាពបន្ទាន់ កម្រនឹងកើតមានឡើងណាស់ ប៉ុន្តែវានៅតែមានសារៈសំខាន់ត្រូវត្រៀមលក្ខណៈជានិច្ច។ ស្ថានភាពគួរឱ្យព្រួយបារម្ភអាចជា ការវង្វេងពេលធ្វើដំណើរតាមមធ្យោបាយសាធារណៈ ឬ មានអារម្មណ៍ថាគ្មានសុវត្ថិភាព។ ខាងក្រោមនេះជាគោលការណ៍ទូទៅមួយចំនួនដែលត្រូវអនុវត្តតាម ប្រសិនបើអ្នកមានអារម្មណ៍មិនកក់ក្ដៅ ឬកំពុងប្រឈមនឹងស្ថានភាពសង្គ្រោះបន្ទាន់។

## ប្រសិនបើវង្វេង ឬ មានអារម្មណ៍ថាគ្មានសុវត្ថិភាព

ប្រសិនបើអ្នកវង្វេង ឬ មានអារម្មណ៍ថាគ្មានសុវត្ថិភាព ឬមានការព្រួយបារម្ភ នោះអ្នកត្រូវទូរសព្ទទៅកាន់ ISC របស់អ្នកភ្លាមៗ។ ISC របស់អ្នកមានតួនាទីជួយអ្នក 24ម៉ោងក្នុងមួយថ្ងៃ 7ថ្ងៃក្នុងមួយសប្ដាហ៍ រួមទាំងក្នុងពេលដែលសាលាឈប់សម្រាកនិងការឈប់សម្រាកជាទូទៅផងដែរ។ មានព័ត៌មានទំនាក់ទំនងលម្អិតនៅលើប័ណ្ណសុវត្ថិភាពសិស្សដែល ISC របស់អ្នកបានផ្ដល់ដល់អ្នកនៅពេលអ្នកមកដល់រដ្ឋវិចតូរីយ៉ា។

## ក្នុងករណីនៃស្ថានភាពសង្គ្រោះបន្ទាន់

សម្រាប់ស្ថានភាពសង្គ្រោះបន្ទាន់ទាំងអស់ ស្ថានភាពគំរាមកំហែងដល់អាយុជីវិត ឬ របួសធ្ងន់ធ្ងរ៖

ចុចលេខ៖ **000**

ចុចលេខ៖ **112** (ហៅចេញពីលេខទូរសព្ទចល័ត បើទោះបីជាទូរសព្ទរបស់អ្នកគ្មានសេវា ឬគ្មានការភ្ជាប់បណ្ដាញក៏ដោយ)។

ប្រសិនបើអ្នកពាក់ព័ន្ធនៅក្នុងស្ថានភាពសង្គ្រោះបន្ទាន់អ្នកត្រូវតែជូនដំណឹងដល់ ISC របស់អ្នកជានិច្ច ក្រុមគ្រួសារផ្ដល់ការស្នាក់នៅតាមផ្ទះ(ប្រសិនបើមាន) សាលាអ្នកកំពុងរៀននិងឪពុកម្ដាយ/អ្នកអាណាព្យាបាលស្របច្បាប់ពីស្ថានភាពនោះ។ សូមរកមើលនៅលើទំព័រស្ដីពីសុខភាពនិងសុវត្ថិភាពនៅលើគេហទំព័រកម្មវិធីសិស្សអន្តរជាតិពីអ្វីដែលត្រូវធ្វើក្នុងអំឡុងស្ថានភាពសង្គ្រោះបន្ទាន់៖ **study.vic.gov.au/en/living-in-victoria/health-and-safety/Pages/default.aspx**

> ប្រសិនបើអ្នកកំពុងស្ថិតនៅក្នុងស្ថានភាពសង្គ្រោះបន្ទាន់ អ្នកត្រូវតែជូនដំណឹងដល់ **ISC** របស់អ្នក, ក្រុមគ្រួសារផ្ដល់ការស្នាក់នៅ (ប្រសិនបើមាន), សាលាដែលអ្នកកំពុងរៀន និងឪពុកម្ដាយ/អ្នកអាណាព្យាបាលស្របច្បាប់របស់អ្នកពីស្ថានភាពនោះជានិច្ច។





# ធនធានព័ត៌មានពីការស្នាក់នៅតាមផ្ទះជាមួយគ្រួសារអូស្ត្រាលី

ព័ត៌មានខាងក្រោមគឺសម្រាប់តែសិស្សដែលបានជ្រើសរើសយកការស្នាក់នៅជាមួយឪពុកម្តាយតាមការណែនាំ ឬក្រុមគ្រួសារអូស្ត្រាលីផ្តល់ការស្នាក់នៅតាមផ្ទះដែលណែនាំដោយពីសាលា។ ព័ត៌មាននេះមិនអនុវត្តចំពោះអ្នកទេ ប្រសិនបើអ្នកជ្រើសរើសរស់នៅជាមួយឪពុកម្តាយ ឬ សាច់ញាតិដែលត្រូវបានអនុម័តដោយក្រសួងអន្តោប្រវេសន៍អូស្ត្រាលី។

## ផ្ទះរបស់អ្នកនៅឆ្ងាយពីស្រុកកំណើតរបស់អ្នក

យើងចង់ឱ្យអ្នកទទួលបាននូវបទពិសោធន៍ប្រសើរបំផុតតាមដែលអាចធ្វើបាននៅពេលអ្នកបញ្ចប់ការសិក្សារបស់អ្នកនៅក្នុងប្រទេសអូស្ត្រាលី។ នេះរួមបញ្ចូលនូវការធានាសុវត្ថិភាពនិងសន្តិសុខពេញមួយរយៈពេលដែលអ្នកកំពុងស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលី។ មគ្គុទេសក៍នេះនឹងផ្តល់ដល់អ្នកនូវធនធាន៖

មានអារម្មណ៍កក់ក្តៅជាមួយក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ

ភ្ជាប់ទំនាក់ទំនងទៅនឹងជំនួយនានាដែលអ្នកត្រូវការដើម្បីរីករាយជាមួយនឹងពេលវេលាកំពុងស្នាក់នៅក្នុងប្រទេសអូស្ត្រាលី

ទទួលបានអត្ថប្រយោជន៍ដ៏ច្រើនលើសលប់ពីបទពិសោធន៍ស្នាក់នៅតាមផ្ទះជាមួយពលរដ្ឋវិចតូរីយ៉ា

### ការណែនាំឱ្យស្គាល់ពីក្រុមគ្រួសារដែលអ្នកត្រូវស្នាក់នៅជាមួយ

ក្រុមគ្រួសារដែលអ្នកត្រូវស្នាក់នៅជាមួយត្រូវបានជ្រើសរើសយ៉ាងប្រុងប្រយ័ត្នដោយសាលារបស់អ្នក និងមានក្រុមគ្រួសារមួយចំនួនធ្លាប់បានទទួលសិស្សអន្តរជាតិឲ្យស្នាក់នៅជាមួយជាច្រើនឆ្នាំមកហើយ។ អ្នកនឹងយល់ថាក្រុមគ្រួសារដែលអ្នកនឹងស្នាក់នៅជាមួយមានភាពរាក់ទាក់ កក់ក្តៅ និងសកម្មនៅក្នុងសហគមន៍ក្នុងមូលដ្ឋាន។ ពួកគេនឹងធានាដល់សុវត្ថិភាព និងភាពសប្បាយរីករាយដូច្នេះអ្នកអាចទទួលបានផលច្រើនបំផុតពីពេលវេលា ដែលអ្នកមាននៅក្នុងរដ្ឋវិចតូរីយ៉ា។ ក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅក៏អាចមានកូនរៀននៅសាលាជាមួយអ្នកផងដែរ។

អ្នកនឹងត្រូវផ្គូរផ្គងជាមួយនឹងក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅយ៉ាងហោចណាស់បួនសប្តាហ៍មុនពេលអ្នកមកដល់។ ព័ត៌មានលម្អិតពីពួកគេនឹងត្រូវផ្ញើទៅកាន់ភ្នាក់ងារអប់រំ ឬឪពុកម្តាយរបស់អ្នកនៅក្នុងសំណុំឯកសារមួយដែលមានឈ្មោះថាសារតាក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅ។ នេះរួមបញ្ចូលទាំងរូបថតផ្ទះដែលត្រូវស្នាក់នៅ និងព័ត៌មានទំនាក់ទំនងលម្អិតសម្រាប់ឪពុកម្តាយដែលអ្នកនឹងត្រូវស្នាក់នៅជាមួយផងដែរ។ វាក៏រាប់បញ្ចូលផងដែរនូវឈ្មោះនិងអាយុរបស់អ្នកគ្រប់គ្នានៅក្នុងក្រុមគ្រួសាររួមទាំងកូនៗនិងសិស្សផ្សេងទៀតផងដែរ។

អ្នកអាចនឹងចង់ស្វែងយល់ថែមបន្តិចទៀតអំពីក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅ និងអាចថែមទាំងទាក់ទងពួកគេមុនពេលមកដល់ប្រទេសអូស្ត្រាលីក៏បានដែរ។ ងាយៗដោយគ្រាន់តែសួរទៅកាន់ ISC របស់អ្នកហើយពួកគេនឹងជួយដល់អ្នករៀបចំនូវទម្រង់ព័ត៌មានទំនាក់ទំនងដ៏ប្រសើរបំផុត។ អ្នកអាចរកឃើញព័ត៌មានទំនាក់ទំនងរបស់ ISC របស់អ្នកនៅក្នុងទម្រង់ជំនួយពេលមកដល់ដែលត្រូវបានផ្ញើចេញនៅក្នុងពេលជាមួយគ្នានឹងសារតាគ្រួសារផ្តល់ការស្នាក់នៅដែរ។

### អ្វីជាការរំពឹងទុកពីក្រុមគ្រួសារដែលអ្នកនឹងស្នាក់នៅជាមួយ

គ្រួសារដែលអ្នកនឹងស្នាក់នៅជាមួយនឹងផ្តល់ដល់អ្នកនូវ៖

- កន្លែងសុវត្ថិភាព សន្តិសុខ និងមានភាពកក់ក្តៅសម្រាប់ការរស់នៅ
- ក្រុមគ្រួសារដែលគោរពតាមស្តង់ដាសុវត្ថិភាពកុមារ
- បន្ទប់មួយដាច់ដោយឡែកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន
- មានអាហារូបត្ថម្ភយ៉ាងតិចបីពេលក្នុងមួយថ្ងៃប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដោយមានលទ្ធភាពសមស្របទទួលបានអាហារសម្រន់ និងអនុលោមតាមតម្រូវការវេជ្ជសាស្ត្រនិងរបបអាហាររបស់សិស្ស
- គ្រឿងបរិក្ខារ – គ្រែមួយ ទូរសម្លៀកបំពាក់មួយកន្សែង និងស្រោមពូក-ខ្នើយ
- សេវាសាធារណៈ – ថ្លៃឧស្ម័ន អគ្គីសនី កម្តៅ និងទឹក អ៊ីនធើណិត
- សេវាសម្អាតអនាម័យនៅទីកន្លែងរស់នៅរួមគ្នា
- ការប្រើប្រាស់ទីធ្លារស់នៅក្នុងបរិវេណលំនៅដ្ឋាន
- បរិក្ខារសិក្សា – តុ អំពូលភ្លើងសម្រាប់សិក្សា ទូរដាក់សៀវភៅ
- ការចូលរួមនៅក្នុងជំនួបមាតាបិតា/គ្រូបង្រៀនជំនួសមុខឪពុកម្តាយរបស់អ្នក។

### លក្ខណៈទូទៅនៃក្រុមគ្រួសារផ្តល់ការស្នាក់នៅ

ប្រទេសអូស្ត្រាលីជាប្រទេសពហុវប្បធម៌ដោយមានភាពខុសៗគ្នាជាច្រើននៅក្នុងរចនាសម្ព័ន្ធគ្រួសារនិងសារតា។ ពុំមាន 'លក្ខណៈទូទៅ' នៃក្រុមគ្រួសារពលរដ្ឋអូស្ត្រាលីទេ ដូច្នេះវាពុំមានអ្វីឱ្យពិតប្រាកដពីលក្ខណៈទូទៅរបស់ក្រុមគ្រួសារផ្តល់ការស្នាក់នៅនោះទេ។

ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយអាចខុសគ្នាទាំងស្រុងពីគ្រួសាររបស់អ្នកផ្ទាល់។ ពួកគេក៏អាចមានលក្ខណៈខុសបន្តិចពីការរំពឹងទុករបស់អ្នកដែរ ហើយក៏មិនប្រាកដជាដូចទៅនឹងក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅរបស់សិស្សានុសិស្សទាំងឡាយផ្សេងទៀតនៅក្នុងកម្មវិធីដែរ។

អ្វីដែលគ្រប់ក្រុមគ្រួសារផ្តល់ការស្នាក់នៅមានជារួមនោះគឺការប្តេជ្ញាផ្តល់នូវបរិយាកាសស្នាក់នៅមួយប្រកបដោយមេត្រីភាព និង សុវត្ថិភាព។សិស្សមួយចំនួនមានការភ្ញាក់ផ្អើលចំពោះប្រភេទនៃក្រុមគ្រួសារផ្សេងៗគ្នានៅក្នុងប្រទេសអូស្ត្រាលី។ ទាំងនេះជាចំណុចមួយចំនួនដែលអាចនឹងខុសគ្នាផ្នែកវប្បធម៌ពីប្រទេសកំណើតរបស់អ្នក។

- ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយអាចជាបុគ្គលនៅលីវ ឬ ជាភរិយាស្វាមីដែលមាន ឬពុំមានកូន។
- នៅក្នុងប្រទេសអូស្ត្រាលីការចែកតួនាទីទៅតាមភេទនៅក្នុងផ្ទះមិនសូវជាមានអាទិភាពដូចនៅក្នុងប្រទេសមួយចំនួនផ្សេងទៀតទេ។ ឪពុកម្តាយទាំងពីរអាចធ្វើម្ហូប និង/ឬសម្អាត ហើយកូនៗក៏ជួយដល់ឪពុកម្តាយនូវការងារជុំវិញផ្ទះដែរ។
- ស្ត្រីច្រើនតែបន្តធ្វើការនៅក្រោយពេលមានគ្រួសារ។
- ប្រទេសអូស្ត្រាលីជាប្រទេសពហុវប្បធម៌ ហើយក្រុមគ្រួសារទាំងឡាយនឹងមានសមាជិកមកពីប្រជាជាតិផ្សេងៗគ្នា។

## ការរស់នៅប្រចាំថ្ងៃជាមួយនឹងក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ

ថ្ងៃធ្វើការជាមធ្យមនៅក្នុងក្រុមគ្រួសារពលរដ្ឋអូស្ត្រាលីអាចនឹងខុសពីប្រទេសកំណើតរបស់អ្នក។ ចំណុចមួយចំនួនអំពីជីវិតប្រចាំថ្ងៃដែលត្រូវពិចារណា។

- ម៉ោងធ្វើការខុសៗគ្នា ប៉ុន្តែច្រើននៅចន្លោះពីម៉ោង 8:00ព្រឹក និងម៉ោង 6:00ល្ងាច។
- ម៉ោងសិក្សានៅសាលាជាធម្មតានៅចន្លោះពីម៉ោង 8:30ព្រឹក និងម៉ោង 3:00រសៀល។
- នៅពេលរសៀលនិងពេលល្ងាច កុមារអូស្ត្រាលីជាច្រើនចូលរួមក្នុងសកម្មភាពនានា ដូចជាកីឡា ឬ មេរៀនតន្ត្រី និងការធ្វើកិច្ចការសាលា។
- ក្រុមគ្រួសារភាគច្រើនឧស្សាហ៍បរិភោគអាហារល្ងាចរួមគ្នា (អាចធ្វើឡើងនៅតុអាហារល្ងាច នៅបង់ក្នុងផ្ទះបាយ ឬ ក៏នៅខាងមុខទូរទស្សន៍)។

សកម្មភាពចុងសប្តាហ៍ក៏អាចមានលក្ខណៈខុសពីអ្វីដែលអ្នកធ្វើនៅឯប្រទេសកំណើតរបស់អ្នកផងដែរ។

- ក្មេងៗនឹងច្រើនតែមានសកម្មភាពសិក្សាក្រៅថ្នាក់បន្ថែមទៀត ដូចជាថ្នាក់រៀនភាសា កីឡា ឬ ការសម្តែងសិល្បៈជាដើម។
- ក្រុមគ្រួសារនឹងធ្វើកិច្ចការផ្ទះរបស់គេ ទិញគ្រឿងទេសក៏ និងត្រៀមទុកមួយសប្តាហ៍មុន។
- គ្រួសារមួយចំនួនអាចនឹងទៅលេងសាច់ញាតិ មិត្តភក្តិ ឬ ចេញទៅខាងក្រៅទៅលេងតាមតំបន់រមណីដ្ឋានទេសចរណ៍នានា។
- យុវវ័យអាចនឹងចំណាយពេលដើរផ្សារ ទៅមើលភាពយន្ត ឬ ដើរលេងជាមួយនឹងមិត្តភក្តិរបស់គេ។

យើងសូមណែនាំដល់អ្នកឱ្យចូលរួមនៅក្នុងសកម្មភាពទាំងនេះ ត្បិតវាជាមធ្យោបាយមួយដ៏អស្ចារ្យដើម្បីឱ្យស្គាល់ពីក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ និងដើម្បីអភិវឌ្ឍជំនាញភាសាអង់គ្លេសរបស់អ្នក។

## លក្ខណៈផ្ទះរបស់ក្រុមគ្រួសារដែលអ្នកនឹងស្នាក់នៅជាមួយ

អ្នកអាចនឹងរស់នៅក្នុង៖

- ផ្ទះដាច់តែឯង
- ផ្ទះជាប់គ្នា
- អាផាតមិន

នៅក្នុងផ្ទះពលរដ្ឋអូស្ត្រាលីជាច្រើន ផ្ទះបាយច្រើនតែស្ថិតនៅចំកណ្តាលនៃសកម្មភាព។ ផ្ទះដែលអ្នកនឹងស្នាក់នៅក៏អាចមានសួនច្បារ ឬ យ៉រខាងមុខដែរ។

## សត្វចិញ្ចឹមរបស់ក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅ

ក្រុមគ្រួសារមួយចំនួនដែលផ្តល់ការស្នាក់នៅ នឹងមានសត្វចិញ្ចឹមដូចជា៖

- ឆ្មា
- ឆ្កែ
- ទន្សាយ
- មាន់ក៏មានដែរ!

អ្នកនឹងត្រូវបានណែនាំឱ្យដឹងពីសត្វចិញ្ចឹមដែលមាននៅក្នុងផ្ទះដែលអ្នកស្នាក់នៅជាមួយ នៅមុនពេលអ្នកមកដល់ប្រទេសអូស្ត្រាលី។ ប្រសិនបើអ្នកមានការព្រួយបារម្ភណាមួយ ឬមានអាឡែកស៊ីជាមួយសត្វចិញ្ចឹម សូមមេត្តាប្រាប់ដល់ ISC របស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើបាន។



> យើងសូមណែនាំឱ្យអ្នកចូលរួមក្នុងសកម្មភាពទាំងនេះត្បិតវាជាមធ្យោបាយមួយដ៏អស្ចារ្យដើម្បីស្គាល់ពីក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅដល់អ្នក និងដើម្បីអភិវឌ្ឍជំនាញភាសាអង់គ្លេសរបស់អ្នក។

# មុនពេលអ្នកមកដល់

## កក់ជើងយន្តហោះរបស់អ្នកមកកាន់ប្រទេសអូស្ត្រាលី

ឪពុកម្តាយ ឬភ្នាក់ងារអប់រំរបស់អ្នកនឹងត្រូវបានតម្រូវឱ្យបំពេញទម្រង់ព័ត៌មានលម្អិតរបស់ក្រសួងពីជើងយន្តហោះ ហើយផ្ញើវាដោយភ្ជាប់ជាមួយនូវច្បាប់ថតចម្លងជាភាសាអង់គ្លេសនៃសំបុត្រយន្តហោះរបស់អ្នកទៅកាន់ក្រសួងឱ្យបានបួនសប្តាហ៍មុនពេលអ្នករំពឹងថានឹងមកដល់ប្រទេសអូស្ត្រាលី។ ការផ្តល់ទម្រង់ព័ត៌មានលម្អិតពីជើងយន្តហោះនឹងជួយដល់សាលាត្រៀមសម្រាប់ការមកដល់របស់អ្នក។

### ការមកដល់ប្រទេសអូស្ត្រាលី

ក្រសួងមិនទទួលខុសត្រូវទៅលើសុខុមាលភាពរបស់អ្នកលើសពីប្រាំពីរថ្ងៃមុននឹងការសិក្សារបស់អ្នកចាប់ផ្តើមឡើយ។ សូមកុំមកដល់ផ្ទះដែលអ្នកត្រូវស្នាក់នៅមុនពេលនេះឱ្យសោះ។

## ម៉ោងមកដល់

សូមធានាឱ្យប្រាកដពីម៉ោងដែលអ្នករំពឹងថានឹងមកនៅចន្លោះពីម៉ោង 6ព្រឹក និងម៉ោង 8ល្ងាច។

## ការមកទទួលនិងការជូនទៅកន្លែងស្នាក់នៅ

នៅពេលអ្នកមកដល់ក្រុងមែលប៊ន ISC របស់អ្នក ឬ សមាជិកម្នាក់នៃបុគ្គលិកសាលារបស់អ្នកនឹងនៅរង់ចាំទទួលអ្នកនៅឯអាកាសយានដ្ឋាន។ ពួកគេក៏អាចនឹងនាំសមាជិកនៃក្រុមគ្រួសារដែលអ្នកត្រូវស្នាក់នៅជាមួយមកផងដែរ។

អ្នកនឹងទទួលបាននូវ ទម្រង់ជំនួយពេលមកដល់ មុនពេលអ្នកចាកចេញពីប្រទេសកំណើតរបស់អ្នក។ ទម្រង់នេះមានព័ត៌មាន៖

- ឈ្មោះសាលាដែលអ្នកត្រូវសិក្សា
- ឈ្មោះបុគ្គលដែលនឹងមកទទួលអ្នកពីអាកាសយានដ្ឋាន
- លេខទូរសព្ទដៃរបស់តំណាងសាលាដែលអ្នកត្រូវសិក្សា
- ភិនភាគរបស់តំណាងសាលារបស់អ្នក ពួកគេក៏នឹងយកប័ណ្ណសម្គាល់ខ្លួនសិស្សមកជាមួយផងដែរនៅពេលគេជួបអ្នកនៅអាកាសយានដ្ឋាន
- រូបថតពីចំណុចត្រូវជួបគ្នាក្នុងអាកាសយានដ្ឋាន
- លេខទំនាក់ទំនង ISC របស់អ្នក
- ព័ត៌មានលម្អិតពេលអាសន្ន

## ការធ្វើដំណើរមកជាមួយក្រុមគ្រួសារអ្នក

ការសិក្សានៅក្រៅប្រទេសគឺជារឿងដ៏អស្ចារ្យមួយ! ក្រុមគ្រួសាររបស់អ្នកអាចនឹងចង់មកឃើញដោយផ្ទាល់ពីកន្លែងដែលអ្នកនឹងរស់នៅ ឬ ក៏មកដើរកំសាន្តនៅក្នុងប្រទេសអូស្ត្រាលីក៏មានដែរ។ នេះពិតជាគ្មានបញ្ហាអ្វីទេ ហើយយើងលើកទឹកចិត្តដល់សិស្សម្នាក់ៗ និងក្រុមគ្រួសាររបស់អ្នកឱ្យធ្វើអ្វីៗដែលប្រសើរបំផុតដើម្បីធានាឱ្យទទួលបាននូវបទពិសោធន៍នៃការមកដល់ជាវិជ្ជមាន។

ទោះជាយ៉ាងណា ត្រូវដឹងថានៅពេលជួបអ្នកនៅអាកាសយានដ្ឋាន សាលារបស់អ្នកមិនទទួលខុសត្រូវចំពោះការដឹកជញ្ជូនមនុស្សបន្ថែម (រួមទាំងសមាជិកក្រុមគ្រួសារ) ទៅកាន់ផ្ទះគ្រួសារដែលអ្នកស្នាក់នៅជាមួយនោះទេ។

ផ្ទះដែលផ្តល់ការស្នាក់នៅដល់អ្នកមិនតម្រូវឱ្យផ្តល់កន្លែងស្នាក់នៅសម្រាប់អ្នកផ្សេងរួមទាំងក្រុមគ្រួសាររបស់អ្នកផងដែរ។ ទោះជាយ៉ាងណាពួកគេនឹងរីករាយជួបជាមួយឪពុកម្តាយរបស់អ្នក ឧទាហរណ៍ដូចជាជួបញ៉ាំអាហារជាមួយគ្នាជាដើម។
ISC របស់អ្នកអាចផ្តល់ការណែនាំពីជម្រើសកន្លែងស្នាក់នៅក្បែរផ្ទះដែលអ្នកស្នាក់នៅប្រសិនបើក្រុមគ្រួសាររបស់អ្នកមកជាមួយអ្នក។

ប្រសិនបើអ្នកមានសមាជិកគ្រួសារធ្វើដំណើរមកប្រទេសអូស្ត្រាលីជាមួយអ្នក សូមផ្តល់ព័ត៌មានឱ្យ ISC របស់អ្នកបានដឹងជាមុន និងផ្តល់នូវព័ត៌មានទំនាក់ទំនងលម្អិតរបស់គេនៅលើទម្រង់ព័ត៌មានពីជើងយន្តហោះ។

## ក្រុមគ្រួសារស្ថិតនៅក្នុងប្រទេសអូស្ត្រាលី

សមាជិកក្រុមគ្រួសារកំពុងរស់នៅក្នុងប្រទេសអូស្ត្រាលីអាចមកទទួលអ្នកពីព្រលានយន្តហោះបានប្រសិនបើអ្នកពេញចិត្ត។ ទោះជាយ៉ាងណា សូមប្រាប់ដល់ ISC របស់អ្នកឱ្យបានដឹងជាមុននិងផ្តល់ដល់ពួកគេនូវព័ត៌មានទំនាក់ទំនងលម្អិតរបស់ពួកគេនៅលើទម្រង់ព័ត៌មានពីជើងយន្តហោះ។

ប្រសិនបើអ្នកត្រូវការជំនួយ ឬមានសំណួរនានាអំពីការមកដល់ក្នុងប្រទេសអូស្ត្រាលីនោះ សូមទាក់ទង ISC របស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

សូមរក្សាទុកទម្រង់ជំនួយពេលមករបស់អ្នកឱ្យនៅជាមួយអ្នកជានិច្ចក្នុងអំឡុងពេលធ្វើដំណើរ។



# ការមកដល់ផ្ទះក្រុមគ្រួសារអូស្ត្រាលីដែលអ្នកត្រូវស្នាក់នៅ

**ការមកដល់ផ្ទះក្រុមគ្រួសារអូស្ត្រាលីដែលអ្នកត្រូវស្នាក់នៅជាមួយ វាជាពេលវេលាមួយដ៏គួរឱ្យរំភើបក្រៃលែង! បន្ទាប់ពីការធ្វើដំណើរដ៏វែងឆ្ងាយ ទីបំផុតទៅអ្នកនឹងមកដល់ផ្ទះនិងជួបជាមួយនឹងសមាជិកក្រុមគ្រួសារអូស្ត្រាលីដែលអ្នកត្រូវស្នាក់នៅជាមួយ។**

នៅពេលអ្នកមកដល់ផ្ទះដែលអ្នកត្រូវស្នាក់នៅជាលើកដំបូង អ្នកនឹងត្រូវបានណែនាំឱ្យស្គាល់ក្រុមគ្រួសារអូស្ត្រាលីដែលអ្នកត្រូវស្នាក់នៅជាមួយនិងបង្ហាញពីអ្វីៗនៅជុំវិញផ្ទះ។ ISC របស់អ្នកនឹងស្ថិតនៅជាមួយអ្នកនិងក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយបន្តិច ដើម្បីជួយអ្នកក្នុងការចូលស្នាក់នៅនិងបញ្ចប់កិច្ចការលិខិតស្នាមមួយចំនួនដែលនៅសេសសល់។

## គន្លឹះដើម្បីឱ្យការមកដល់មានលក្ខណៈប្រកបដោយភាពវិជ្ជមាន

យើងសង្ឃឹមថា អ្នកនឹងរំភើបរីករាយនៅពេលមកដល់ផ្ទះក្រុមគ្រួសារអូស្ត្រាលីដែលអ្នកត្រូវស្នាក់នៅជាមួយ។ ក្នុងពេលនោះដែរជាធម្មតាអ្នកមានការអស់កម្លាំងក្រោយការធ្វើដំណើរដ៏វែងឆ្ងាយ ហើយអ្នកក៏នឹងអាចយល់ថាវាច្រើនលើសលប់ពេក ឬក៏មានការនឹករឭកដល់ស្រុកកំណើតខ្លះៗផងដែរ។

ទាំងនេះជាគន្លឹះមួយចំនួន ដែលយើងសូមណែនាំដល់អ្នកនៅរយៈពេលប៉ុន្មានម៉ោងក្រោយការមកដល់៖

- ទាក់ទងទៅកាន់ក្រុមគ្រួសាររបស់អ្នកនៅឯប្រទេសកំណើត។ និយាយសួរសុខទុក្ខនិងប្រាប់ដល់ពួកគេឱ្យបានដឹងថាអ្នកបានមកដល់ដោយសុវត្ថិភាពហើយ។
- រកអ្វីញ៉ាំបន្តិចបន្តួច (ក្រុមគ្រួសារដែលអ្នកត្រូវស្នាក់នៅជាមួយនឹងមានអាហារ ឬអាហារសម្រន់ខ្លះត្រៀមសម្រាប់ពេលអ្នកមកដល់)។
- ងូតទឹកនិងផ្លាស់ប្តូរសម្លៀកបំពាក់ថ្មី។
- សម្រាក – សង្ងំគេងបន្តិច ឬ ទម្រេតខ្លួន។
- ចាប់ផ្តើមជួបស្វែងយល់ជាមួយក្រុមគ្រួសារដែលអ្នកត្រូវស្នាក់នៅជាមួយ ហើយណែនាំខ្លួនអ្នកខ្លះៗដល់ពួកគេ។
- ក្រុមគ្រួសារដែលអ្នកត្រូវស្នាក់នៅជាមួយអាចនឹងសុំជូនអ្នកដើរទស្សនាកន្លែងនានាក្នុងមូលដ្ឋាន ដែលនេះជារឿងល្អត្រូវធ្វើនៅក្នុងថ្ងៃទីមួយរបស់អ្នក។

អ្នកអាចនឹងមានអារម្មណ៍ថាអស់កម្លាំង តែមិនត្រូវសម្ងំនៅក្នុងបន្ទប់របស់អ្នកឡើយ។ ចាប់ផ្តើមស្គាល់ពីក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយនឹងកាន់តែងាយស្រួលប្រសិនបើអ្នកប្រឹងប្រែងចំណាយពេលជាមួយពួកគេ។

# ការចាប់ផ្តើមស្គាល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ

## ភាពខុសគ្នាផ្នែកភាសានិងវប្បធម៌

ការយល់ ការនិយាយ និងការសរសេរជាភាសាអង់គ្លេសអាចត្រូវប្រើពេលមួយចំនួន។ មធ្យោបាយរៀនតែមួយគត់គឺត្រូវអនុវត្តវា!
ដើម្បីបន្តជួយដល់អ្នក យើងមានសំណូមពរពីរ៖

- កុំធ្វើរឿងឱ្យវាស្មុគស្មាញពេក៖ វាមិនជាបញ្ហាអ្វីទេដែលគ្រាន់តែប្រើភាសាសាមញ្ញ និងឃ្លាខ្លីៗ។
- អនុវត្តវា៖ កុំខ្លាចទំនាក់ទំនងបើទោះជាក្នុងពេលដែលអ្នកមិនដឹងច្បាស់ពីពាក្យដែលត្រឹមត្រូវបំផុតត្រូវប្រើក៏ដោយ។
- ទាញយកអែបបកប្រែភាសា៖ បច្ចេកវិទ្យាគឺជាមិត្តរបស់អ្នក! ទាញយកអែបបកប្រែភាសារបស់ហ្គូហ្គោល ដើម្បីជួយអ្នកនៅពេលជួបបញ្ហា។

> បើទោះជាអ្នកអាចនឹងអស់កម្លាំងក៏ពិតមែន តែសូមព្យាយាមកុំនៅតែក្នុងបន្ទប់របស់អ្នក។ ចាប់ផ្តើមស្គាល់ពីក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយនឹងកាន់តែងាយស្រួលប្រសិនបើអ្នកប្រឹងប្រែងចំណាយពេលនៅជាមួយពួកគេ។



# ជីវិតស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលី

**នេះជាគោលការណ៍ណែនាំទូទៅមួយចំនួនតូច អំពីជីវិតស្នាក់នៅតាមផ្ទះជាមួយពលរដ្ឋអូស្ត្រាលី ដើម្បីជួយអ្នកឱ្យមានអារម្មណ៍កក់ក្តៅ និងធានាថាម្នាក់ៗនិងមានបទពិសោធន៍ជាវិជ្ជមានក្នុងអំឡុងការស្នាក់នៅរបស់អ្នក។**

គោលការណ៍ណែនាំទាំងនេះអនុវត្តបាននៅគ្រប់ក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅទាំងអស់។

## ទឹកញ៉ាំ

ប្រព័ន្ធទឹកស្អាតប្រទេសអូស្ត្រាលីពិតជាមានសុវត្ថិភាពអាចញ៉ាំបាន។ ទឹកញ៉ាំប្រើតម្រង ឬ ទឹកញ៉ាំដបពិតជាមិនចាំបាច់ឡើយនៅក្នុងប្រទេសអូស្ត្រាលី។

## អាហារ

អាហារអូស្ត្រាលីមានលក្ខណៈខុសៗគ្នាយ៉ាងសម្បូរបែប។ គ្រប់គ្រួសារទំនងជានឹងមានមុខម្ហូបខុសៗគ្នា និងញ៉ាំម្ហូបប្រភេទខុសៗគ្នានៅក្នុងសប្តាហ៍។

ទាំងនេះជាអាហារនិងម្ហូបដែលក្រុមគ្រួសារអូស្ត្រាលីជាទូទៅអាចនឹងញ៉ាំ៖

- **អាហារព្រឹក៖** នំប៉័ងអាំង, សៀរៀល, សៀរៀលលាយគ្រាប់ធញ្ញជាតិ, ទឹកដោះគោជូរ
- **អាហារសម្រន់ពេលព្រឹក៖** ផ្លែឈើ សៀរៀលបន្ទះ ទឹកដោះគោជូរ ឈីស និង នំស្រួយ
- **អាហារថ្ងៃត្រង់៖** នំសែនវិចនិងផ្លែឈើចំណិត ឬអាហារដូចជាសាច់និងបន្លែដែលអាចកំដៅក្នុងម៉ៃក្រូវ៉េវនៅសាលាបាន
- **អាហារសម្រន់ពេលរសៀល៖** ផ្លែឈើ សៀរៀលបន្ទះ មី បន្លែចំណិត ឈីសនិង នំស្រួយ
- **អាហារល្ងាច៖** បាយ ឬ ផាស្តាញ៉ាំជាមួយសាច់និងបន្លែ
- **អាហារសម្រន់ពេលយប់៖** ភេសជ្ជៈក្តៅៗ (ឧ.ទា. តែ, សូកូឡាក្តៅ), នំផ្អែមមួយចំណិត ឬនំប៊ីស្គីត

អាចនឹងមានភាពខុសគ្នារវាងអាហារដែលអ្នកធ្លាប់ញ៉ាំតាំងពីកើតមកនិងអាហារដែលមាននៅផ្ទះក្រុមគ្រួសារអូស្ត្រាលីដែលអ្នកស្នាក់នៅជាមួយ។

> ត្រូវប្រាប់ដល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយឱ្យបានដឹងជានិច្ចពីល័ក្ខខណ្ឌតម្រូវផ្នែកអាហារ ឬអាឡែកស៊ីនានាដែលអ្នកមាន។

នៅតាមក្រុមគ្រួសារពលរដ្ឋអូស្ត្រាលីជាច្រើន វាជារឿងធម្មតាដែលគេត្រូវចម្អិនអាហារល្ងាចឱ្យលើសបន្តិច ដើម្បីឱ្យសិស្សអាចខ្ចប់យកខ្លះសម្រាប់អាហារថ្ងៃត្រង់នៅថ្ងៃបន្ទាប់បាន។ សាលារបស់អ្នកនឹងមានម៉ៃក្រូវ៉េវ ដូច្នេះហើយអ្នកអាចកំដៅអាហារថ្ងៃត្រង់របស់អ្នកបាន។

## សម្ភារប្រើប្រាស់សម្រាប់ការញ៉ាំនិងហាន់

សម្ភារប្រើប្រាស់សម្រាប់ការញ៉ាំនិងហាន់ជារួមរបស់អូស្ត្រាលីអាចនឹងមិនដូចគ្នាទៅនឹងអ្វីដែលអ្នកប្រើប្រាស់នៅឯប្រទេសកំណើតរបស់អ្នក។ ពលរដ្ឋអូស្ត្រាលីភាគច្រើនបរិភោគដោយប្រើកាំបិត សម និងស្លាបព្រា។ អ្នកអាចរកទិញបានជានិច្ចនូវសម្ភារប្រើប្រាស់សម្រាប់ញ៉ាំផ្ទាល់ខ្លួន ឬ ក៏ប្រើរបស់យើងក៏បានដែរ!

## សម្ភារប្រើប្រាស់ក្នុងផ្ទះ

កុំក្រែងនឹងសួរពីរបៀបប្រើប្រាស់របស់របរក្នុងផ្ទះនៅពេលអ្នកត្រូវការវា។ អ្វីៗគ្រប់យ៉ាងដែលមាន រាប់ចាប់តាំងពីម៉ាស៊ីនបោកគក់រហូតដល់កំសៀវដាំទឹកអាចនឹងត្រូវប្រើប្រាស់ខុសគ្នាតិចតួចពីអ្វីដែលអ្នកធ្លាប់ប្រើពីមុនមក។ ជារឿងល្អនោះ គឺត្រូវសួរបញ្ជាក់ជាមួយក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយមុននឹងចាប់ផ្តើមប្រើប្រាស់របស់របរទាំងនោះ។

## កម្រាលពូកនិងរបស់របរផ្សេងទៀត

យ៉ាងតិចបំផុតក៏ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយនឹងផ្តល់ឱ្យអ្នក៖

- ខ្នើយនិងស្រោមខ្នើយ
- កម្រាលពូកលើក្រោម
- ភួយពួក និងស្រោម

រដ្ឋវិចតូរីយ៉ាអាចចុះត្រជាក់ខ្លាំងនៅក្នុងរដូវរងា ដូច្នេះសូមសុំភួយបន្ថែមពីក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ ប្រសិនបើអ្នកមិនទាន់កក់ក្តៅគ្រប់គ្រាន់ទេនោះ។

ប្រសិនបើអ្នកមិនហ៊ាននិយាយដោយផ្ទាល់ជាមួយពួកគេទេ សូមទាក់ ISC របស់អ្នកឱ្យជួយ។

## ភាពស្អាតនៅក្នុងផ្ទះ

ក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅភាគច្រើនរំពឹងថាគ្រប់គ្នានឹងជួយការងារផ្ទះ។ ការងារនេះរួមមានការសម្អាតនិងរៀបចំផ្ទះឱ្យមានសណ្តាប់ធ្នាប់។ អ្នកអាចនឹងត្រូវសុំឱ្យជួយរៀបចំតុអាហារ លាងចាន ឬដាក់ចានចូលក្នុងម៉ាស៊ីនលាងចាន និងរក្សាកន្លែងផ្ទាល់ខ្លួនរបស់អ្នកឱ្យមានសណ្តាប់ធ្នាប់។ ក្រុមគ្រួសារពលរដ្ឋអូស្ត្រាលីកម្រមានជួលមនុស្សឱ្យជួយការងារផ្ទះដូចជាចម្អិនអាហារ ឬ សម្អាតផ្ទះណាស់។

## សីលធម៌ក្នុងការប្រើប្រាស់បន្ទប់ទឹក

ទឹកត្រូវបានចាត់ជាធនធានកម្រមួយនៅក្នុងប្រទេសអូស្ត្រាលី ដោយមានក្រុមគ្រួសារជាច្រើនមានវិធានការបន្ថែមដើម្បីសន្សំសំចៃទឹក។ សូមយកចិត្តទុកដាក់ក្នុងរឿងនេះនៅពេលប្រើប្រាស់បន្ទប់ទឹក។ សូមពិចារណាដល់ឧត្តមានុវត្តដូចខាងក្រោម។

- ជៀសវាងការងូតទឹកដោយប្រើផ្កាឈូកលើសពី 15 នាទី។ ការងូតទឹកដោយប្រើផ្កាឈូកប្រសើរបំផុតនោះគឺពី 5–10នាទី។
- កុំទុកឱ្យទឹកហូរចោលនៅពេលអ្នកកំពុងដុសធ្មេញ។
- សូមបិទទឹកឱ្យបានត្រឹមត្រូវជាប្រចាំ។
- ទម្លាក់តែក្រដាសអនាម័យបន្ទប់ទឹកចូលក្នុងបង្គន់។ អ្វីៗផ្សេងពីនេះនឹងធ្វើឱ្យស្ទះបន្ទប់ទឹក។
- មិនត្រូវអង្គុយចោងហោងលើបង្គន់ជាដាច់ខាត៖ វាអាចនឹងបែក ហើយអាចនឹងបង្ករបួសស្នាមដល់ខ្លួនអ្នក។

## ការបោកគក់

ជាការល្អអ្នកត្រូវពិភាក្សាការបោគគក់ជាមួយនឹងគ្រួសារដែលអ្នកស្នាក់នៅជាមួយ។ នៅក្នុងក្រុមគ្រួសារមួយចំនួន ឪពុកម្តាយធ្វើការងារបោកគក់ច្រើនជាងគេ ប៉ុន្តែនៅក្នុងក្រុមគ្រួសារផ្សេងទៀតកូនៗ (ជាពិសេសកូនៗក្នុងវ័យជំទង់) ជួយក្នុងការងារនេះ រួមទាំងការដាក់សម្លៀកបំពាក់ចូលទៅក្នុងម៉ាស៊ីនបោកខោអាវ យកវាទៅហាលលើខ្សែនិងការប្រមូលវាទុកនៅពេលស្ងួត។ តាមគ្រួសារពលរដ្ឋអូស្ត្រាលី ដោយសារតែអាកាសធាតុល្អខ្លាំងបែបនេះ ពួកគេច្រើនតែហាលសម្លៀកបំពាក់នៅក្រៅផ្ទះជំនួសឱ្យការប្រើប្រាស់ម៉ាស៊ីនសម្ងួត។ ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយនឹងបង្ហាញអ្នកពីរបៀបប្រើប្រាស់ទាំងនេះ។

ប្រសិនបើអ្នកអាចធ្វើបានខ្លះ ឬ ទាំងអស់នៃការងារបោកគក់ដោយខ្លួនឯងនោះ នេះពិតជាការប្រសើរណាស់។

## វិន័យក្នុងផ្ទះ

ផ្ទះនីមួយៗនឹងមានការកំណត់ពីការរំពឹងទុកដាច់ដោយឡែកពីគ្នាដែលនឹងត្រូវផ្តល់ដល់អ្នកជាលម្អិតដោយសាលារបស់អ្នក។ វិន័យក្នុងផ្ទះរបស់ក្រុមគ្រួសារដែលផ្តល់ការស្នាក់នៅអាចនឹងរួមបញ្ចូលនូវ៖

- ឥរិយាបទ
- ការងារសម្អាត/ការងារផ្ទះ
- ការប្រើប្រាស់សម្ភាររួម (e.g. បន្ទប់ទឹក, ផ្ទះបាយ, ម៉ាស៊ីនបោកគក់)
- បម្រាម
- ត្រូវមានការអនុញ្ញាតពេលគេងនៅក្រៅផ្ទះ (នៅឆ្ងាយពីផ្ទះដែលអ្នកស្នាក់នៅ)
- ដើរលេងខាងក្រៅជាមួយមិត្តភក្តិ
- ភ្ញៀវមកលេង



## សុវត្ថិភាពផ្ទាល់ខ្លួន និងការទំនាក់ទំនង

ត្រូវផ្តល់ដំណឹងដល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ និង ISC របស់អ្នកពីកាលវិភាគនិងកន្លែងដែលអ្នកស្ថិតនៅជាប្រចាំ។

វាជារឿងសំខាន់ត្រូវជម្រាបដល់ក្រុមគ្រួសារអ្នកស្នាក់នៅជាមួយឱ្យបានដឹង ប្រសិនបើអ្នកមិនត្រឡប់មកផ្ទះវិញ និងត្រូវសុំការអនុញ្ញាតប្រសិនបើអ្នកចង់ចេញដើរលេងខាងក្រៅជាមួយមិត្តភក្តិ។

ប្រសិនបើអ្នកវង្វេងដោយចៃដន្យពេលចេញក្រៅផ្ទះ ឬយល់ថាគ្មានសុវត្ថិភាពនោះ សូមទាក់ទងក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ ឬ ទាក់ទងទៅកាន់ ISC របស់អ្នកភ្លាមៗ។

នៅពេលអ្នកមកដល់រដ្ឋវិចតូរីយ៉ា ISC របស់អ្នកនឹងផ្តល់ដល់អ្នកនូវប័ណ្ណសុវត្ថិភាពសិស្ស ដែលមានលេខទូរសព្ទសម្រាប់ទំនាក់ទំនងពេលស្ថិតក្នុងស្ថានភាពអាសន្ន។ សូមរក្សាវាជាប់ខ្លួនអ្នកគ្រប់ពេលទាំងអស់។ វាក៏មានសារៈសំខាន់ផងដែរត្រូវថតរូបប័ណ្ណសុវត្ថិភាពសិស្សទុកក្នុងទូរសព្ទរបស់អ្នក។

ប្រសិនបើអ្នកមានការព្រួយបារម្ភទាក់ទងនឹងបទពិសោធន៍ស្នាក់នៅតាមផ្ទះជាមួយក្រុមគ្រួសារអូស្ត្រាលី ឬ សាលានោះ សូមប្រាប់ដល់ ISC គ្រូ ឬ នាយកសាលារបស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើបាន។

### ការបង់ថ្លៃឈ្នួលផ្ទះ

**ដំណើរការបង់ថ្លៃឈ្នួលផ្ទះ**

ការបង់ថ្លៃឈ្នួលទាំងអស់គួរតែត្រូវធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច។ ប្រសិនបើអ្នកមានបញ្ហាណាមួយ ISC របស់អ្នកអាចពិភាក្សាជាមួយនឹងក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ និងឪពុកម្តាយ/អ្នកអាណាព្យាបាលស្របច្បាប់អំពីការបង់ថ្លៃឈ្នួលជំនួសអ្នក។

> មានឱកាសជាច្រើនពេញមួយឆ្នាំដើម្បីស្វែងយល់ពីប្រទេសអូស្ត្រាលី ឬ មានគម្រោងត្រឡប់ទៅលេងប្រទេសកំណើតរបស់អ្នក។ ប្រសិនបើអ្នកមានគម្រោងធ្វើដំណើរក្នុងអំឡុងពេលសាលាឈប់សម្រាក អ្នកចាំបាច់ត្រូវតែប្រាប់ដល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ និង ISC របស់អ្នកឱ្យឆាប់បានដឹងតាមដែលអាចធ្វើបាន។

## ការធ្វើដំណើរ, ការស្នាក់នៅខាងក្រៅពេលយប់ និងភ្ញៀវមកលេង

### ការមកលេងរបស់ក្រុមគ្រួសារ

ដូចជាក្នុងករណីដែលសមាជិកក្រុមគ្រួសារបានមកដល់ប្រទេសអូស្ត្រាលីជាមួយអ្នក ប្រសិនបើក្រុមគ្រួសាររបស់អ្នកចង់មកលេងនៅពេលក្រោយអ្វីដែលសំខាន់នោះគឺថាអ្នកត្រូវជូនដំណឹងដល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយនិងសាលារបស់អ្នក។ ផ្ទះដែលអ្នកស្នាក់នៅជាមួយមិនតម្រូវឱ្យផ្តល់ការស្នាក់នៅដល់នរណាម្នាក់ផ្សេងឡើយរួមទាំងក្រុមគ្រួសាររបស់អ្នកផងដែរ តែទោះជាយ៉ាងណាពួកគេនឹងពេញចិត្តជួបជាមួយឪពុកម្តាយរបស់អ្នក ឧទាហរណ៍ដូចជាការជួបញ៉ាំអាហារជាដើម។ ISCរបស់អ្នកអាចផ្តល់យោបល់ពីកន្លែងស្នាក់នៅសមស្របនៅជិតផ្ទះដែលអ្នកស្នាក់នៅ ប្រសិនបើក្រុមគ្រួសាររបស់អ្នកចង់មកលេង។

### ការស្នាក់នៅក្រៅផ្ទះពេលយប់

ប្រសិនបើអ្នកចង់ស្នាក់នៅក្រៅផ្ទះពេលយប់ ឧទាហរណ៍នៅជាមួយក្រុមគ្រួសាររបស់មិត្តភក្តិនោះ អ្នកត្រូវតែទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរទាំងពីរក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ និងឪពុកម្តាយ/អ្នកអាណាព្យាបាលស្របច្បាប់របស់អ្នក។ ពិភាក្សាជាមួយនឹង ISC របស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើបានដើម្បីមានពេលគ្រប់គ្រាន់សម្រាប់រៀបចំ។

### ផែនការធ្វើដំណើរពេលឈប់សម្រាក

មានឱកាសជាច្រើនពេញមួយឆ្នាំដើម្បីស្វែងយល់ពីអូស្ត្រាលី ឬ ធ្វើផែនការត្រឡប់ទៅលេងប្រទេសកំណើត។ ប្រសិនបើអ្នកមានគម្រោងធ្វើដំណើរក្នុងអំឡុងពេលសាលាឈប់សម្រាក អ្នកចាំបាច់ត្រូវតែប្រាប់ដល់ក្រុមគ្រួសារដែលអ្នកស្នាក់នៅជាមួយ និង ISC របស់អ្នកឱ្យឆាប់បានដឹងតាមដែលអាចធ្វើបាន។
គោលនយោបាយធ្វើដំណើររបស់សិស្សកំណត់ថា សាលារបស់អ្នកត្រូវតែសម្រេចលើរាល់ការធ្វើដំណើររួមទាំងដំណើរកម្សាន្តផងដែរ ដើម្បីធានាដល់សុវត្ថិភាពនិងសុខុមាលភាពរបស់អ្នកគ្រប់ពេលទាំងអស់។ ការធ្វើដំណើរមិនត្រូវបានអនុញ្ញាតក្នុងអំឡុងពេលសាលាកំពុងដំណើរការនោះទេ។

### និងជាចុងក្រោយ...

យើងសង្ឃឹមថាព័ត៌មាននេះបានឆ្លើយទៅនឹងសំណួររបស់អ្នកអំពីអ្វីដែលជាបទពិសោធន៍ក្នុងការស្នាក់នៅជាមួយក្រុមគ្រួសារអូស្ត្រាលីរបស់អ្នក។

យើងមានក្តីរំភើបជាខ្លាំងដែលអ្នកបានជ្រើសរើសមកសិក្សាជាមួយយើងនឹងទន្ទឹងរង់ចាំស្វាគមន៍អ្នកដោយរាក់ទាក់កក់ក្តៅមកកាន់ក្រុងមែលប៊ន និងក្រុងនានាដែលសិស្សានុសិស្សរបស់យើងរស់នៅទូទាំងរដ្ឋវិចតូរីយ៉ា!

ជួបគ្នាឆាប់ៗខាងមុខនេះ!



# ព័ត៌មានមានប្រយោជន៍

ថ្វីបើអ្នកបានត្រៀមខ្លួនរួចរាល់សម្រាប់ជីវិតនៅក្នុងរដ្ឋវិចតូរីយ៉ាក៏ដោយ ជាការល្អអ្នកត្រូវដឹងពីកន្លែងដែលអ្នកអាចរកព័ត៌មានបាន។ សូមប្រើប្រាស់ព័ត៌មានទំនាក់ទំនងលម្អិតនិងធនធានអនឡាញដើម្បីទទួលបានជំនួយឱ្យបានឆាប់និងងាយស្រួល។

## សេវាកម្ម

**ស្ថានភាពបន្ទាន់៖ ប៉ូលីស រថយន្តសង្គ្រោះបន្ទាន់ អគ្គិភ័យ**
ស្នើសុំប៉ូលីស រថយន្តសង្គ្រោះបន្ទាន់ឬអគ្គិភ័យ។
នេះជាលេខទូរសព្ទហៅចូលមិនគិតថ្លៃ ហើយអ្នកបកប្រែភាសាក៏មានផ្ដល់ជូនដែរ ប្រសិនបើអ្នកត្រូវការ។
ចុចលេខ៖ 000
ចុចលេខ៖ 112 (ពីទូរសព្ទដៃ)
ចុចលេខ៖ 106 (ពីទូរសព្ទផ្ញើសារជាអក្សរ TDD)

**មិនបន្ទាន់៖ ប៉ូលីស**
ចុចលេខ៖ 131 444
គេហទំព័រ៖ police.vic.gov.au

**ការិយាល័យពន្ធដារអូស្ត្រាលី**
**ដាក់ពាក្យស្នើសុំលេខប្រកាសពន្ធ**
ចុចលេខ៖ 13 28 65
គេហទំព័រ៖ ato.gov.au

**ជំនួយផ្នែកច្បាប់រដ្ឋវិចតូរីយ៉ា**
**សេវាព័ត៌មានផ្នែកច្បាប់**
ចុចលេខ៖ 1300 792 387
គេហទំព័រ៖ legalaid.vic.gov.au

**ស្ថានទូតបរទេសនានានៅក្នុងរដ្ឋវិចតូរីយ៉ា**
ចុចលេខ៖ 02 6261 1111
គេហទំព័រ៖ dfat.gov.au/about-us/foreign-embassies/pages/foreign-embassies-and-consulates-in-australia

## ការសិក្សានៅក្នុងរដ្ឋវិចតូរីយ៉ា

**ក្រសួងអប់រំនិងបណ្ដុះបណ្ដាលផ្នែកអប់រំអន្តរជាតិ**
អ៊ីម៉ែល៖ international@education.vic.gov.au
គេហទំព័រ៖study.vic.gov.au

**វិញ្ញាបនបត្រអប់រំរដ្ឋវិចតូរីយ៉ា (VCE) និងការចូលរៀននៅឧត្តមសិក្សា**
សម្រាប់ព័ត៌មានបន្ថែមអំពីការវាយតម្លៃការសិក្សានៅក្នុងរដ្ឋវិចតូរីយ៉ា៖
គេហទំព័រ៖ https://vcaa.vic.edu.au/Pages/HomePage.aspx

## សុខភាព និង វេជ្ជសាស្ត្រ

**សុវត្ថិភាពសិស្ស**
សម្រាប់ព័ត៌មានអំពីសុវត្ថិភាពសិស្សនិងអ្វីដែលត្រូវធ្វើក្នុងស្ថានភាពសង្គ្រោះបន្ទាន់៖
គេហទំព័រ៖ study.vic.gov.au/enliving-in-victoria/health-and-safetypages/default.aspx

**ធានារ៉ាប់រងសុខភាព**
គេហទំព័រ៖ https://www.studyaustralia.gov.au/en/plan-your-move/overseas-student-health-cover-oshc.html

**ទូរសព្ទទៅកាន់គិលានុបដ្ឋាយិកាប្រចាំការ**
ចុចលេខ៖1300 60 60 24

**មជ្ឈមណ្ឌលព័ត៌មានពីការពុលនៅរដ្ឋវិចតូរីយ៉ា**
ចុចលេខ៖ 13 11 26

**Lifeline Australia**
ជាខ្សែទូរសព្ទផ្ដល់ជំនួយពេលមានវិបត្តិ និងសេវាសុខភាពផ្លូវចិត្ត 24ម៉ោង៖
ចុចលេខ៖ 13 11 14
គេហទំព័រ៖ lifeline.org.au

## គេហទំព័រមានប្រយោជន៍

**ប្រាក់និងធនាគារ**
គេហទំព័រ៖ moneysmart.gov.au

**ប្រៃសណីយ៍អូស្ត្រាលី**
រួមបញ្ចូលនូវទីតាំងប៉ុស្តិ៍ប្រៃសណីយ៍ទាំងអស់៖
គេហទំព័រ៖ auspost.com.au

**ម៉ោងនិងកាលបរិច្ឆេទ**
ពិនិត្យមើលម៉ោងនៅក្នុងប្រទេសរបស់អ្នក ឬ ម៉ោងនៅក្នុងរដ្ឋវិចតូរីយ៉ា៖
គេហទំព័រ៖ timeanddate.com/worldclock

**ការចំណាយលើការរស់នៅ**
សម្រាប់ការប៉ាន់ស្មានថ្លៃសិស្សនិងចំណាយផ្សេងៗបច្ចុប្បន្ន៖
គេហទំព័រ៖ www.study.vic.gov.au/en/international-student-program/school-fees/pages/default.aspx

## ទេសន្តរប្រវេសន៍ និង ទិដ្ឋាការ

**ក្រសួងអន្តោប្រវេសន៍**
ចុចលេខ៖ 131 881
គេហទំព័រ៖ homeaffairs.gov.au

## ការដឹកជញ្ជូន

**ផែនទីផ្លូវ និង ទិសដៅ**
គេហទំព័រ៖ google.com/maps

**អាកាសយានដ្ឋានក្រុងមែលប៊ន**
អាកាសយានដ្ឋានក្រុងមែលប៊ន និងក្រុងអាវ៉ាឡុន – អាកាសយានចរណ៍អន្តរជាតិនិងក្នុងស្រុក៖
គេហទំព័រ៖ melbourneairport.com.au
គេហទំព័រ៖ avalonairport.com.au

**រថយន្តក្រុងអាកាសយានដ្ឋានក្រុងមែលប៊ន**
រថយន្តក្រុងស្កាយប៊ីសធ្វើប្រតិបត្តិការរវាងអាកាសយានដ្ឋានក្រុងមែលប៊ននិងមជ្ឈមណ្ឌលក្រុង៖
គេហទំព័រ៖ skybus.com.au

**មធ្យោបាយធ្វើដំណើរសាធារណៈ៖ PTV**
ចុចលេខ៖ 1800 800 007
គេហទំព័រ៖ ptv.vic.gov.au

## ទេសចរណ៍

**ធ្វើទេសចរណ៍ជុំវិញរដ្ឋវិចតូរីយ៉ា**
គេហទំព័រ៖ visitvictoria.com

**ការធ្វើទេសចរណ៍ក្នុងក្រុងមែលប៊ន**
គេហទំព័រ៖ whatson.melbourne.vic.gov.au
គេហទំព័រ៖ visitmelbourne.com

**ការរស់នៅនិងធ្វើការនៅក្នុងរដ្ឋវិចតូរីយ៉ា**
ដើម្បីស្វែងរកព័ត៌មានបន្ថែមអំពីការរស់នៅនិងធ្វើដំណើរក្នុងរដ្ឋវិចតូរីយ៉ា៖
គេហទំព័រ៖ liveinmelbourne.vic.gov.au

**មគ្គុទេសក៍សិស្សអន្តរជាតិក្រុងមែលប៊ន**
គន្លឹះដើម្បីឱ្យទទួលបានអត្ថប្រយោជន៍ច្រើនបំផុតក្នុងនាមជាសិស្សរស់នៅក្នុងក្រុងមែលប៊ន៖
គេហទំព័រ៖ melbourne.vic.gov.au

### កម្មវិធីកុំព្យូទ័រមានប្រយោជន៍នានាដែលត្រូវទាញយកមកប្រើប្រាស់

មួយចំនួននៃកម្មវិធីកុំព្យូទ័រទាំងនេះនឹងមិនមានទេនៅក្នុងប្រទេសកំណើតរបស់អ្នក ប៉ុន្តែពួកគេអាចមានប្រយោជន៍ក្រោយពេលអ្នកបានមកដល់។

**ប្រព័ន្ធផ្សព្វផ្សាយសង្គម៖**
WeChat, Facebook, Instagram

**ការកម្សាន្តសប្បាយ៖**
Spotify, YouTube

**កម្មវិធីផ្ញើសារ៖**
WhatsApp, Facebook Messenger

**សុខភាពផ្លូវចិត្ត៖**
Headspace

**មធ្យោបាយធ្វើដំណើរសាធារណៈ៖**
PTV, Tram Tracker

**ការបកប្រែភាសា៖**
ការបកប្រែតាមហ្គូហ្គោល

**ផែនទី៖**
ផែនទីហ្គូហ្គោល

យើងសង្ឃឹមថាព័ត៌មាននៅក្នុងមគ្គុទេសក៍នេះមានប្រយោជន៍ក្នុងការត្រៀមខ្លួនសម្រាប់ការសិក្សារបស់អ្នកនៅក្នុងរដ្ឋវិចតូរីយ៉ា។ សូមកុំភ្លេចមើលគេហទំព័រទាំងឡាយដែលយើងបានផ្ដល់ជូនដើម្បីទាញយកប្រយោជន៍ជាអតិបរមាពីការរស់នៅក្នុងរដ្ឋវិចតូរីយ៉ានិងក្រុងមែលប៊ន។

ប្រសិនបើអ្នកមានសំណួរ ឬត្រូវការជំនួយ សូមទាក់ទងផ្នែកអប់រំអន្តរជាតិតាមរយៈinternational@education.vic.gov.au ឬទាក់ទងទៅកាន់អ្នកសម្របសម្រួលសិស្សអន្តរជាតិរបស់សាលាលោកអ្នក។

សូមមានសំណាងល្អជាមួយនឹងការត្រៀមខ្លួនរបស់អ្នក ហើយយើងទន្ទឹងរង់ចាំស្វាគមន៍អ្នកមកកាន់រដ្ឋវិចតូរីយ៉ា នាពេលឆាប់ៗខាងមុខនេះ។



## សាលារដ្ឋវិចតូរីយ៉ា

**កម្មវិធីសិស្សអន្តរជាតិ**

ក្រសួងអប់រំនិងបណ្តុះបណ្តាល

GPO Box 4367, Melbourne Victoria 3001, Australia

អ៊ីម៉ែល៖ international@education.vic.gov.au

គេហទំព័រ៖ study.vic.gov.au

ឈ្មោះនិងលេខកូដអ្នកផ្តល់ CRICOS៖
ក្រសួងអប់រំនិងបណ្តុះបណ្តាល, 00861K

VICTORIA
State Government
Australia